# នៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង
# នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

**ព័ត៌មានពិស្តារនៃការដាក់ឯកសារ**

| | | |
|---|---|---|
| សំណុំរឿងលេខ | : | ០០២/១៩-០៩-២០០៧-អវតក/អជសង |
| ដាក់ទៅ | : | អង្គជំនុំជម្រះសាលាដំបូង |
| ថ្ងៃដាក់ | : | ថ្ងៃទី១៥ ខែមិថុនា ឆ្នាំ២០១១ |
| ភាគីអ្នកដាក់ | : | សហព្រះរាជអាជ្ញា |
| ភាសាដើម | : | **អង់គ្លេស** |

ឯកសារបកប្រែ
TRANSLATION/TRADUCTION
ថ្ងៃ ខែ ឆ្នាំ (Date): 15-Jun-2011, 15:38
CMS/CFO: Kauv Keoratanak

**ចំណាត់ថ្នាក់ឯកសារ**

ប្រភេទឯកសារដែលស្នើឡើងដោយភាគីដាក់ឯកសារ: **សាធារណៈ**

ចំណាត់ថ្នាក់ឯកសារកំណត់ដោយការិ.សហចៅក្រមស៊ើបអង្កេត ឬអង្គជំនុំជម្រះ: សាធារណៈ/Public

ប្រភេទនៃចំណាត់ថ្នាក់ឯកសារ:

ការពិនិត្យចំណាត់ថ្នាក់ឯកសារបណ្តោះអាសន្នឡើងវិញ:

ឈ្មោះមន្ត្រីដែលបានពិនិត្យ:

ហត្ថលេខា:

---

## សំណើរបស់សហព្រះរាជអាជ្ញា សុំឲ្យអង្គជំនុំជម្រះសាលាដំបូង ដកលក្ខខណ្ឌតម្រូវស្តីពីទំនាក់ទំនងនៃជម្លោះប្រដាប់អាវុធចេញពីនិយមន័យនៃ ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ

---

| **អ្នកដាក់ឯកសារ:** | **អ្នកទទួលឯកសារ:** | **ចម្លងជូន:** |
|---|---|---|
| សហព្រះរាជអាជ្ញា: | អង្គជំនុំជម្រះសាលាដំបូង: | ជនជាប់ចោទ: |
| លោកស្រី ជា លាង | ចៅក្រម និល ណុន, ប្រធាន | នួន ជា |
| លោក Andrew CAYLEY | ចៅក្រម Silvia CARTWRIGHT | អៀង សារី |
| | ចៅក្រម យ៉ា សុខន | អៀង ធីរិទ្ធ |
| | ចៅក្រមJean-Marc LAVERGNE | ខៀវ សំផន |
| | ចៅក្រម ធូ មណី | |

| | |
|---|---|
| **សហមេធាវីនាំមុខតំណាងដើមបណ្ដឹងរដ្ឋប្បវេណី:** | **មេធាវីការពារក្ដីជនជាប់ចោទ:** |
| ពេជ អង្គ | លោក សុន អរុណ |
| Elisabeth SIMONNEAU FORT | លោក Michiel PESTMAN |
| | លោក Victor Koppe |
| | លោក អាង ឧត្ដម |
| | លោក Michael G.KARNAVAS |
| | លោក ផាត់ ពៅស៊ាង |
| | កញ្ញា Diana ELLIS QC |
| | លោក ស សូវាន |
| | លោក Jacques VERGÈS |

# I. សេចក្តីផ្តើម

១- អនុលោមតាមវិធាន ៩២ និង ៩៨.២[1] សហព្រះរាជអាជ្ញាសូមដាក់សារណានេះ ដើម្បីគាំទ្រចំពោះសំណើរបស់ខ្លួន ដែលស្នើឱ្យអង្គជំនុំជម្រះសាលាដំបូង កែតម្រូវលើនិយមន័យច្បាប់នៃឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ដែលមានចែងនៅក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះ ទៅតាមការធ្វើវិសោធនកម្មដោយអង្គបុរេជំនុំជម្រះ តាមរយៈការដកចេញនូវលក្ខខណ្ឌតម្រូវស្តីពីទំនាក់ទំនងរវាងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ និងជម្លោះប្រដាប់អាវុធ[2]។

២- ក្នុងសំណុំរឿងលេខ០០១ អង្គជំនុំជម្រះសាលាដំបូងបានរកឃើញថា ទំនាក់ទំនងជាមួយនឹងជម្លោះប្រដាប់អាវុធ ពុំមែនជាលក្ខខណ្ឌតម្រូវសម្រាប់ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិទេ នៅក្រោមច្បាប់ទំនៀមទម្លាប់អន្តរជាតិ នៅក្នុងអម្លុងពេលនៃយុត្តាធិការពេលវេលារបស់ អ.វ.ត.ក។ ការវាយតម្លៃអំពីច្បាប់របស់អង្គជំនុំជម្រះសាលាដំបូង គឺជាការត្រឹមត្រូវ និងគួរតែត្រូវបានប្រើប្រាស់នៅក្នុងសំណុំរឿងលេខ០០២ ផងដែរ។ ដូចបានរៀបរាប់យ៉ាងលម្អិតនៅខាងក្រោមនេះ អវត្តមាននៃលក្ខខណ្ឌតម្រូវអំពីទំនាក់ទំនងនៃជម្លោះប្រដាប់អាវុធ គឺជាការសមរម្យ ដោយសារ (១)មាត្រា៥នៃច្បាប់ អ.វ.ត.កដែលចែងកំណត់និយមន័យជាធរមានអំពីឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ពុំមានលក្ខខណ្ឌតម្រូវអំពីទំនាក់ទំនងរវាងអំពើជាដើមអាទិ៍ និងជម្លោះប្រដាប់អាវុធទេ; (២)គ្មានលក្ខខណ្ឌតម្រូវអំពីទំនាក់ទំនងនៃជម្លោះប្រដាប់អាវុធ សម្រាប់ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិទេ នៅក្នុងច្បាប់ទំនៀមទម្លាប់អន្តរជាតិនៅក្នុងអម្លុងឆ្នាំ១៩៧៥-១៩៧៩; និង (៣)គេអាចព្យាករទុកជាមុនថា ជនជាប់ចោទអាចនឹងត្រូវបានដាក់ឱ្យទទួលខុសត្រូវចំពោះឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ដែលបានប្រព្រឹត្តឡើងនៅក្នុងប្រទេសកម្ពុជាក្រៅជម្លោះប្រដាប់អាវុធ ហើយព័ត៌មានចាំបាច់សម្រាប់ការសន្និដ្ឋាននេះ ក៏បានក្លាយជាសាធារណៈ និងអាចរកបានរួចរាល់ហើយដែរ។

៣- សហព្រះរាជអាជ្ញាសូមស្នើបន្ថែមទៀតថា អង្គជំនុំជម្រះជូនដំណឹងដល់ភាគី នៅមុនពេលចាប់ផ្តើមសវនាការថា បទចោទអំពីឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ដែលមាននៅក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះ

[1] វិធានផ្ទៃក្នុង អ.វ.ត.ក, វិសោធនកម្មលើកទី៧, ២៣ កុម្ភៈ ឆ្នាំ២០១១ [ចាប់ពីនេះតទៅហៅថា "វិធាន អ.វ.ត.ក"], វិធាន ៩២, ៩៨ ។

[2] សហព្រះរាជអាជ្ញាពីមុនបានបង្ហាញពីឆន្ទៈរបស់ខ្លួនលើកពីបញ្ហានេះនៅក្នុងសវនាការបឋម។ *សូមអាន* សេចក្តីជូនដំណឹងរបស់សហព្រះរាជអាជ្ញាអំពីបញ្ហាច្បាប់ដែលខ្លួនមានបំណងចង់លើកនៅពេលសវនាការបឋម, សំណុំរឿងលេខ: ០០២/១៩-០៩-២០០៧-អវតក/អជសង, E9/30, ១៩ មេសា ២០១១, កថាខណ្ឌ ១(៩)(ក) ។

អាចនឹងបញ្ជាក់ភស្តុតាងបាន ដោយពុំចាំបាច់បង្ហាញអំពីទំនាក់ទំនងទៅនឹងជម្លោះប្រដាប់អាវុធឡើយ។ ទោះបីជាអង្គជំនុំជម្រះមានឆន្ទានុសិទ្ធិសម្រេចលើបញ្ហានេះនៅដំណាក់កាលចុងក្រោយក្តី ក៏សហព្រះរាជអាជ្ញាសន្និដ្ឋានថា ការជូនដំណឹងជាមុននឹងរួមចំណែកដល់សមត្ថភាពនៃដំណើរការនីតិវិធី ដែលការណ៍នេះនឹងអនុញ្ញាតឲ្យអង្គជំនុំជម្រះ និងភាគីនានាផ្តោតលើពេលវេលា និងការយកចិត្តទុកដាក់របស់ខ្លួនទៅលើបញ្ហាដែលពាក់ព័ន្ធខ្លាំងបំផុតនៅក្នុងសំណុំរឿង។

## II. ប្រវត្តិនីតិវិធី

៤- នៅថ្ងៃទី១៥ ខែកញ្ញា ឆ្នាំ២០១០ សហចៅក្រមស៊ើបអង្កេតបានចេញដីកាដំណោះស្រាយ នៅក្នុងសំណុំរឿងលេខ០០២ ដែលក្នុងនោះបានដាក់បញ្ចូលឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ អនុលោមតាមមាត្រា៥ នៃច្បាប់ អ.វ.ត.ក[3]។ គ្រប់ជនជាប់ចោទទាំងបួននាក់ បានប្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ ដោយឈរលើទទ្ទីករណ៍ខុសៗគ្នា។ ជនជាប់ចោទពីរនាក់ក្នុងចំណោមនេះ បានប្តឹងឧទ្ធរណ៍ប្រឆាំងនឹងនិយមន័យនៃឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ដែលបានប្រើនៅក្នុងដីកាដំណោះស្រាយ។ ដើមបណ្តឹងឧទ្ធរណ៍ អៀង សារី តវ៉ាថា "ក.ស.ច.ស មានការភាន់ច្រឡំ តាមរយៈការខកខានមិនបានពន្យល់ថា ទំនាក់ទំនងរវាងអំពើជាដើមអាទិ៍ និងជម្លោះប្រដាប់អាវុធអន្តរជាតិ គឺជាលក្ខខណ្ឌតម្រូវមួយនៃឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិនៅ អ.វ.ត.ក"[4]។ ដើមបណ្តឹងឧទ្ធរណ៍ អៀង ធីរិទ្ធ តវ៉ាថា ក.ស.ច.ស មានការភាន់ច្រឡំតាមរយៈការខកខានមិនបានរកឃើញថា"អត្ថិភាពនៃជម្លោះប្រដាប់អាវុធ"គឺជាធាតុផ្សំមួយនៃនិយមន័យនៃឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ នៅក្នុងអម្លុងពេលនៃយុត្តាធិការពេលវេលារបស់អ.វ.ត.ក"[5]។ សហ-ព្រះរាជអាជ្ញាបានដាក់ចម្លើយតបរួមរបស់ខ្លួនទៅនឹងបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយរបស់ នួន ជា អៀង សារី និង អៀង ធីរិទ្ធ នៅថ្ងៃទី១៩ ខែវិច្ឆិកា ឆ្នាំ២០១០[6]។

---

[3] ដីកាដំណោះស្រាយ, ការិយាល័យសហចៅក្រមស៊ើបអង្កេត, D427, ១៥ កញ្ញា ២០១០, កថាខណ្ឌទី ១៦១៣ ។

[4] បណ្តឹងឧទ្ធរណ៍របស់ អៀង សារី ប្រឆាំងនឹងដីកាដំណោះស្រាយ, សំណុំរឿងលេខ: ០០២/១៩-០៩-២០០៧-អវតក/កសចស (អបជ ៧៥), D427/1/6, ២៥ តុលា ២០១០, កថាខណ្ឌទី ១៨៨ ។

[5] បណ្តឹងឧទ្ធរណ៍របស់មេធាវីការពារក្តី អៀង ធីរិទ្ធ ពីដីកាដំណោះស្រាយ, សំណុំរឿងលេខ: ០០២/១៩-០៩-២០០៧-អវតក/កសចស (អបជ ១៤៥), D427/2/1, ១៨ តុលា ២០១០, កថាខណ្ឌទី ៦១ ។

[6] ចម្លើយតបរួមរបស់សហព្រះរាជអាជ្ញា ទៅនឹងបណ្តឹងឧទ្ធរណ៍របស់ នួន ជា, អៀង សារី និង អៀង ធីរិទ្ធ ប្រឆាំងនឹងដីកាដំណោះស្រាយ, សំណុំរឿងលេខ: ០០២/១៩-០៩-២០០៧-អវតក/កសចស (អបជ ៧៥ & ១៤៥ & ១៤៦), ១៩ វិច្ឆិកា ២០១០ [ចាប់ពីនេះតទៅហៅថា "ចម្លើយតបរួមរបស់ ក.ស.ព"] ។ សហព្រះរាជអាជ្ញាបានដាក់ចម្លើយតបដាច់ដោយឡែកមួយទៅនឹងបណ្តឹងឧទ្ធរណ៍របស់ ខៀវ សំផន ប្រឆាំងនឹងដីកាដំណោះស្រាយ ។

៥- នៅថ្ងៃទី១៣ ខែមករា ឆ្នាំ២០១១ អង្គបុរេជំនុំជម្រះបានចេញសេចក្ដីសម្រេចបឋម លើបណ្ដឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយទាំងនេះ ដែលក្នុងនោះ អង្គបុរេជំនុំជម្រះបានសម្រេចថា សហចៅក្រមស៊ើបអង្កេត គួរតែបានគិតគូរថា "នៅក្នុងអម្លុងពេលនៃយុត្តាធិការពេលវេលារបស់ អ.វ.ត.ក ច្បាប់ទំនៀមទម្លាប់អន្តរជាតិ តម្រូវឲ្យមានទំនាក់ទំនងរវាងអំពើជាដើមអាទិ៍នៃឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ និងជម្លោះប្រដាប់អាវុធ"[7]។ ទន្ទឹមនេះដែរ អង្គបុរេជំនុំជម្រះក៏បានធ្វើការកែប្រែដីកាដំណោះស្រាយទាក់ទិននឹងជនជាប់ចោទម្នាក់ៗតាមរយៈការបន្ថែម "អត្ថិភាពនៃទំនាក់ទំនងរវាងអំពើជាដើមអាទិ៍ និងជម្លោះប្រដាប់អាវុធ" និងលក្ខខណ្ឌ "គ្រប់ទាំងអស់" នៅក្នុងជំពូក ៤(ក) នៃផ្នែកទី៣នៃដីកាដំណោះស្រាយ[8]។

## III. អំពីបញ្ហាបឋម

៦- ដោយអនុលោមតាមគោលការណ៍ស្ដីពី *iura novit curia* ("the judge knows the law") "ចៅក្រមចេះច្បាប់" ដែលមានចែងក្នុងវិធាន៩៨.២ នៃវិធានផ្ទៃក្នុងសម្រាប់ អវតក អង្គជំនុំជម្រះសាលាដំបូងមានការទទួលខុសត្រូវចុងក្រោយក្នុងការធានាលើភាពត្រឹមត្រូវនៃការអនុវត្តច្បាប់នៅ អវតក។ ការទទួលខុសត្រូវនេះ លាតសន្ធឹងដល់សេចក្ដីចែងនៃធាតុផ្សំតាមច្បាប់នៃឧក្រិដ្ឋកម្មនានា នៅក្រោមយុត្តាធិការរបស់ អវតក រួមទាំង ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិផង។ ដូច្នេះហើយ អង្គជំនុំជម្រះសាលាដំបូងមានអំណាច

[7] សាលដីការបស់អង្គបុរេជំនុំជម្រះ លើបណ្ដឹងឧទ្ធរណ៍របស់ អៀង ធីរិទ្ធ និង នួន ជា ប្រឆាំងនឹងដីកាដំណោះស្រាយ, សំណុំរឿងលេខ: ០០២/១៩-០៩-២០០៧-អវតក/កសចស (អបជ ១៤៥ & អបជ ១៤៦), D427/2/12, ១៣ មករា ២០១១, កថាខណ្ឌទី១១(១) ។ សាលដីការបស់អង្គបុរេជំនុំជម្រះ លើបណ្ដឹងឧទ្ធរណ៍របស់ អៀង សារី ប្រឆាំងនឹងដីកាដំណោះស្រាយ, សំណុំរឿងលេខ: ០០២/១៩-០៩-២០០៧-អវតក/កសចស (អបជ ៧៥), D427/1/26, ១៣ មករា ២០១១, កថាខណ្ឌទី៧(១) ។ សាលដីការបស់អង្គបុរេជំនុំជម្រះ លើបណ្ដឹងឧទ្ធរណ៍របស់ ខៀវ សំផន ប្រឆាំងនឹងដីកាដំណោះស្រាយ, សំណុំរឿងលេខ: ០០២/១៩-០៩-២០០៧-អវតក/កសចស (អបជ ១០៤), ១៣ មករា ២០១១, កថាខណ្ឌទី២(១) ។

[8] *ក្នុងឯកសារដដែលដូចខាងលើ* ។ ជាបន្តបន្ទាប់មកទៀត អង្គបុរេជំនុំជម្រះបានចេញសេចក្ដីសម្រេចពេញលេញលើបណ្ដឹងឧទ្ធរណ៍ទាំងឡាយប្រឆាំងនឹងដីកាដំណោះស្រាយ ដែលបានរៀបរាប់ពិស្ដារពីមូលហេតុនៃការសម្រេចរបស់ខ្លួនស្ដីពីទំនាក់ទំនងនៃជម្លោះប្រដាប់អាវុធ ។ សាលដីការបស់អង្គបុរេជំនុំជម្រះ លើបណ្ដឹងឧទ្ធរណ៍របស់ អៀង សារី ប្រឆាំងនឹងដីកាដំណោះស្រាយ, សំណុំរឿងលេខ: ០០២/១៩-០៩-២០០៧-អវតក/កសចស (អបជ ៧៥), D427/1/30, ១១ មេសា ២០១១ [ចាប់ពីនេះតទៅហៅថា "សាលដីការបស់ អបជ លើបណ្ដឹងឧទ្ធរណ៍របស់ អៀង សារី ប្រឆាំងនឹងដីកាដំណោះស្រាយ ចុះថ្ងៃទី១១ មេសា ២០១១"], កថាខណ្ឌទី៣០០-៣១៣ ។ សាលដីការបស់អង្គបុរេជំនុំជម្រះ លើបណ្ដឹងឧទ្ធរណ៍របស់ នួន ជា និង អៀង ធីរិទ្ធ ប្រឆាំងនឹងដីកាដំណោះស្រាយ, សំណុំរឿងលេខ: ០០២/១៩-០៩-២០០៧-អវតក/កសចស (អបជ ១៤៥ & អបជ ១៤៦), ១៥ កុម្ភៈ ២០១១ [ចាប់ពីនេះតទៅហៅថា "សាលដីការបស់ អបជ លើបណ្ដឹងឧទ្ធរណ៍របស់ នួន ជា និង អៀង ធីរិទ្ធ ប្រឆាំងនឹងដីកាដំណោះស្រាយ ចុះថ្ងៃទី១៥ កុម្ភៈ ២០១១"], កថាខណ្ឌទី១៣៤-១៤៨ ។ សាលដីការបស់អង្គបុរេជំនុំជម្រះ លើបណ្ដឹងឧទ្ធរណ៍របស់ ខៀវ សំផន ប្រឆាំងនឹងដីកាដំណោះស្រាយ, សំណុំរឿងលេខ: ០០២/១៩-០៩-២០០៧-អវតក/កសចស (អបជ ១០៤), ២១ មករា ២០១១, D427/4/15 កថាខណ្ឌទី២(១) ។

និងកាតព្វកិច្ចកែតម្រូវនិយមន័យនៃឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ដែលបានថ្លែងនៅក្នុងដីកាដំណោះស្រាយដែលបានធ្វើវិសោធនកម្ម ដោយការដកចេញនូវលក្ខខណ្ឌតម្រូវស្ដីពីទំនាក់ទំនងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ។

៧- សហព្រះរាជអាជ្ញាទទួលស្គាល់ថា របៀបដែលការកែសម្រួលនេះត្រូវកើតឡើង គឺត្រូវតែស្របទៅនឹងសិទ្ធិរបស់ជនជាប់ចោទក្នុងការទទួលបាននូវការកាត់សេចក្ដីដ៏ត្រឹមត្រូវ ដែលបានចែងក្នុងវិធាន៣៥នៃច្បាប់ អវតក គឺថាជនជាប់ចោទ "ត្រូវបានទទួលព័ត៌មានភ្លាមៗ និងលម្អិតជាភាសាដែលខ្លួនយល់បានអំពីប្រភេទ និងមូលហេតុនៃការចោទប្រកាន់ចំពោះខ្លួន" ហើយ "មានពេលវេលា និងលក្ខណៈគ្រប់គ្រាន់ដើម្បីរៀបចំការពារខ្លួន និងទាក់ទងជាមួយមេធាវីរបស់ខ្លួនដែលជ្រើសរើសដោយខ្លួនឯង"[9]។ នៅក្នុងបរិបទនេះ សហព្រះរាជអាជ្ញាសូមជូនសេចក្ដីសន្និដ្ឋានថា យុត្តិសាស្ត្រអន្តរជាតិដែលមានជាប់ទាក់ទងនឹងការកំណត់បទចោទលើអង្គហេតុនានាសាជាថ្មីឡើងវិញ អាចណែនាំឲ្យអនុវត្តបាន។

៨- ដោយអនុលោមតាមយុត្តិសាស្ត្រនៃតុលាការសិទ្ធិមនុស្សអឺរ៉ុប ការកំណត់បទចោទសាជាថ្មីឡើងវិញលើឧក្រិដ្ឋកម្មនានាដែលបានចោទប្រកាន់នៅក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះ គឺត្រូវបានអនុញ្ញាត ដរាបណាជនជាប់ចោទត្រូវបានផ្ដល់ដំណឹងជាមុនអំពីលទ្ធភាពដែលថា គេអាចនឹងផ្លាស់ប្ដូរការកំណត់បទចោទលើអង្គហេតុនានា និងអំពីកាលានុវត្តភាព ដើម្បីរៀបចំការការពារខ្លួនទៅតាមនោះ ដោយរួមទាំងការធ្វើសារណាដោយផ្ទាល់មាត់ និងជាលាយលក្ខណ៍អក្សរនៅលើបញ្ហាដែលមានជាប់ទាក់ទងនោះផង[10]។ ក្នុងការអនុវត្តនូវបទដ្ឋាននេះ ការបញ្ជាក់ឡើងវិញអំពីធាតុផ្សំតាមច្បាប់នៃឧក្រិដ្ឋកម្មណាមួយ ដូចជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិជាដើម គឺវាមានលក្ខណៈស្របតាមយ៉ាងច្បាស់លាស់ទៅនឹងសិទ្ធិរបស់ជនជាប់ចោទក្នុងការទទួលបាននូវការកាត់សេចក្ដីដ៏ត្រឹមត្រូវ បើសិនជាជនជាប់ចោទរូបនោះបានដឹងអំពីលទ្ធភាពដែលថា អង្គជំនុំជម្រះសាលាដំបូងអាចនឹងធ្វើការបកស្រាយច្បាប់ជាធរមានផ្សេងគ្នាពីសហចៅក្រមស៊ើបអង្កេត ឬ អង្គបុរេជំនុំជម្រះ ហើយនិងមានកាលានុវត្តភាពក្នុងការធ្វើសារណានានាស្ដីពីបញ្ហាពាក់ព័ន្ធផ្សេងៗ ព្រមទាំងមានការប៊ិនប្រសប់ក្នុងការការពារទៅតាមនោះដែរ។

---

[9] ច្បាប់ អវតក, វិធាន ៣៥ ។

[10] *សូមមើល, ឧទា. Pelissier និង Sassi ទល់នឹង ប្រទេសបារាំង* [GC], 25444/94, ថ្ងៃទី២៥ មីនា ១៩៩៩, កថាខណ្ឌទី ៤២, ៦២ ។ *Sipavicius ទល់នឹង Lithuania,* EctHR (no. 49094/99), ថ្ងៃទី២១ កុម្ភៈ ២០០២, កថាខណ្ឌទី ២៦, ៣១-៣២ ។ *I.H. និងអ្នកដទៃ ទល់នឹង ប្រទេសអូទ្រីស,* ECHR (no. 42780/98), ថ្ងៃទី២០ មេសា ២០០៦, កថាខណ្ឌទី ៣៤ ។

៩- សហព្រះរាជអាជ្ញាសូមជូនសេចក្តីសន្និដ្ឋានថា ជនជាប់ចោទគឺកំពុងតែបានដឹងអំពីលទ្ធភាពដែលថា អង្គជំនុំជម្រះសាលាដំបូងអាចនឹងមិនធ្វើការពិចារណាថា លក្ខខណ្ឌតម្រូវស្តីពីទំនាក់ទំនងជម្លោះប្រដាប់អាវុធ គឺជាធាតុផ្សំមួយក្នុងចំណោមធាតុផ្សំនានាដែលគេតម្រូវឲ្យមានចំពោះឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិនៅ អវតក។ ជនជាប់ចោទត្រូវបានផ្តល់ដំណឹងជាមុនអំពីលទ្ធភាពនេះ តាមរយៈវត្តមាននៃសេចក្តីសន្និដ្ឋានរបស់សហព្រះរាជអាជ្ញា,ការបញ្ជាក់អំពីចេតនាពីមុនៗរបស់សហព្រះរាជអាជ្ញាក្នុងការស្វែងរកការកំណត់បទចោទសាជាថ្មីឡើងវិញ, អង្គហេតុដែលថាបញ្ហាអំពីលក្ខខណ្ឌតម្រូវស្តីពីទំនាក់ទំនងជម្លោះប្រដាប់អាវុធ ត្រូវបានដាក់ពាក្យប្តឹងនៅដំណាក់កាលមុនជំនុំជម្រះ និងបង្កើតបានជាមូលដ្ឋាននៃការធ្វើវិសោធនកម្មមួយទៅលើដីកាដំណោះស្រាយដើមដំបូង, ព្រមទាំងអង្គហេតុដែលថា អង្គជំនុំជម្រះសាលាដំបូង មិនបានតម្រូវឲ្យមានទំនាក់ទំនងជម្លោះប្រដាប់អាវុធមួយទៅនឹងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិទេនៅក្នុងសាលក្រមរបស់ខ្លួនក្នុងសំណុំរឿងលេខ ០០១។ តាមដូចដែលតម្រូវការនៅក្នុងការត្រៀមរៀបចំឲ្យបានគ្រប់គ្រាន់ សហព្រះរាជអាជ្ញាកត់សម្គាល់ថាបញ្ហានេះធ្លាប់ត្រូវបានលើកឡើងរួចហើយនៅមុនមានការចាប់ផ្តើមសវនាការ ហើយជនជាប់ចោទនឹងមានកាលានុវត្តភាពក្នុងការដាក់ជូននូវទស្សនៈនានារបស់ខ្លួនស្តីពីលក្ខខណ្ឌតម្រូវជម្លោះប្រដាប់អាវុធ ជាការឆ្លើយតបទៅនឹងសេចក្តីសន្និដ្ឋានបច្ចុប្បន្ននេះ។

១០- ដោយមានទាក់ទងនឹងខាងលើនេះ ការថ្លែងសេចក្តីឡើងវិញអំពីនិយមន័យនៃឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិនៅក្នុងសាលក្រម (ឲ្យតែមានការដកចេញនូវលក្ខខណ្ឌតម្រូវស្តីពីទំនាក់ទំនងជម្លោះប្រដាប់អាវុធ) អាចត្រូវគ្នាទាំងស្រុងទៅនឹងសិទ្ធិរបស់ជនជាប់ចោទ ក្នុងការទទួលបាននូវការកាត់សេចក្តីដ៏ត្រឹមត្រូវ។ ទោះជាយ៉ាងដូច្នេះក៏ដោយ ដើម្បីចៀសវាងនូវលទ្ធភាពនៃភាពមិនប្រាកដណាមួយនោះ សហព្រះរាជអាជ្ញាសូមស្នើឲ្យ អង្គជំនុំជម្រះសាលាដំបូងធ្វើការសម្រេចលើបញ្ហាលក្ខខណ្ឌតម្រូវស្តីពីទំនាក់ទំនងជម្លោះប្រដាប់អាវុធ ឲ្យបានមុនការចាប់ផ្តើមដំណើរការនីតិវិធីជំនុំជម្រះ ឬមួយក៏ធ្វើសេចក្តីបញ្ជាក់តាមផ្លូវការណាមួយថា ខ្លួនបានយកតាមសំណើរបស់សហព្រះរាជអាជ្ញាដែលកំពុងផ្តល់ប្រឹក្សានេះហើយ។

## IV. **អំណះអំណាង**

### ក. អង្គជំនុំជម្រះសាលាដំបូង បានសន្និដ្ឋានយ៉ាងត្រឹមត្រូវនៅក្នុងសំណុំរឿងលេខ ០០១ ថានិយមន័យតាមច្បាប់ទំនៀមទម្លាប់នៃឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ នៅក្នុងអំឡុងឆ្នាំ១៩៧៥-១៩៧៩ មិនបានដាក់បញ្ចូលលក្ខខណ្ឌតម្រូវនៃជម្លោះប្រដាប់អាវុធទេ

១១- អង្គជំនុំជម្រះសាលាដំបូង បានវាយតម្លៃពីមុនអំពីបញ្ហាច្បាប់ទាក់ទងនឹងនិយមន័យនៃឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិនៅក្នុងសាលក្រមនៃសំណុំរឿងលេខ០០១[11]។ ដោយបានលើកយោងនូវច្បាប់ អ.វ.ត.ក លិខិតុបករណ៍អន្តរជាតិ និងយុត្តិសាស្ត្ររបស់តុលាការអន្តរជាតិដទៃទៀត អង្គជំនុំជម្រះសាលាដំបូងបានកំណត់ថា សញ្ញាណនៃឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិបានកើតមានឡើង ដោយមិនចំណុះទៅនឹងជម្លោះប្រដាប់អាវុធទេ ក្នុងអម្លុងពេលនៃយុត្តាធិការពេលវេលារបស់អ.វ.ត.ក[12]។ ទន្ទឹមនេះ អង្គជំនុំជម្រះសាលាដំបូងបានសម្រេចថា "កង្វះនៃទំនាក់ទំនងណាមួយជាមួយនឹងជម្លោះប្រដាប់អាវុធ នៅក្នុង មាត្រា៥ នៃច្បាប់ អ.វ.ត.ក គឺវាអនុលោមទៅតាមនិយមន័យជាទម្លាប់នៃឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ នៅក្នុងអម្លុងពេលនៃសម័យកាលឆ្នាំ១៩៧៥ ដល់ឆ្នាំ១៩៧៩"[13]។

១២- ការសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងលើបញ្ហាទំនាក់ទំនងនៅក្នុងសំណុំរឿងលេខ ០០១ គឺជាការត្រឹមត្រូវ ហើយសហព្រះរាជអាជ្ញាសន្និដ្ឋានថា និយមន័យច្បាប់ដដែលនៃអំពីឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ គួរតែបានប្រើប្រាស់នៅក្នុងសំណុំរឿងលេខ ០០២។ នៅខណៈដែលអង្គជំនុំជម្រះសាលាដំបូង មិនជាប់កាតព្វកិច្ចទៅនឹងសេចក្ដីសម្រេចរបស់ខ្លួនក្នុងសំណុំរឿងលេខ០០១យ៉ាងណាក្ដី ក៏នៅក្នុងប្រព័ន្ធច្បាប់ខ្លះ អង្គជំនុំជម្រះសាលាដំបូងត្រូវមានការទទួលខុសត្រូវជាទូទៅមួយ ក្នុងការបង្កើតអង្គយុត្តិសាស្ត្រស៊ីសង្វាក់គ្នាមួយ ដែលអនុញ្ញាតឲ្យមានភាពប្រាកដប្រជាផ្នែកច្បាប់។ តាមរយៈការប្រកាន់គោលជំហរស៊ីសង្វាក់គ្នាលើនិយមន័យជាធរមាន អំពីនិយមន័យនៃឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិទាំងនៅក្នុងសំណុំរឿងលេខ០០១ និង០០២ អង្គជំនុំជម្រះសាលាដំបូងនឹងជួយលើកកម្ពស់ស្ថិរភាពច្បាប់លើកទឹកចិត្តចំពោះសមត្ថភាពតុលាការ និងធ្វើឲ្យមានសង្គតិភាពនៃទម្លាប់នៃការអនុវត្តនៅ អ.វ.ត.ក ជាមួយនឹងទម្លាប់នៃការអនុវត្តរបស់តុលាការអន្តរជាតិដទៃទៀត ដូចតុលាការយុត្តិធម៌អន្តរជាតិជាដើម ដែលអនុវត្តនូវករណីយុត្តិសាស្ត្រពីមុនៗរបស់ខ្លួនជាប្រចាំនោះ[14]។

---

[11] *ករណីរឿងរបស់ កាំង ហ្គេកអ៊ាវ* ហៅ *ឌុច*, សាលក្រម, សំណុំរឿងលេខ: ០០១/១៨-០៧-២០០៧-អវតក/អជសដ, ២៦ កក្កដា ២០១០, ERN 00572517-00572797, កថាខណ្ឌទី ២៨១-២៩៦ [ចាប់ពីនេះតទៅហៅថា "សាលក្រមសំណុំរឿងលេខ ០០១"] ។

[12] សាលក្រមសំណុំរឿងលេខ ០០១, កថាខណ្ឌទី ២៩១-២៩៣ ។

[13] សាលក្រមសំណុំរឿងលេខ ០០១, កថាខណ្ឌទី ២៩២ ។

[14] ទោះបីមាត្រា៥៩ នៃច្បាប់លក្ខន្តិកៈនៃតុលាការយុត្តិធម៌អន្តរជាតិ ("ច្បាប់លក្ខន្តិកៈនៃតុលាការ ICJ") ចែងថា ករណីយុត្តិសាស្ត្រពីមុនៗរបស់តុលាការ "គ្មានចំណងកាតព្វកិច្ច លើកលែងតែរវាងគូភាគី និងទាក់ទងតែនឹងករណីជាក់លាក់នោះ" ក៏ដោយ ក៏មាត្រា៣៨(១)(៣) នៃច្បាប់លក្ខន្តិកៈនៃតុលាការ ICJ កំណត់ថា តុលាការអាចពិចារណាអំពីករណីយុត្តិសាស្ត្រពីមុនៗរបស់ខ្លួនបានទុកជា "មធ្យោបាយបុគ្រសម្ព័ន្ធសម្រាប់ការកំណត់អំពីវិធាននៃច្បាប់"។ ច្បាប់លក្ខន្តិកៈនៃតុលាការយុត្តិធម៌អន្តរជាតិ, ២៦ មិថុនា ១៩៤៥, ១៥៦ U.N.T.S 77 ។ ក្នុងទម្លាប់

១៣- សហព្រះរាជអាជ្ញាសន្និដ្ឋានបន្ថែមទៀតថា អំណះអំណាងរបស់អង្គបុរេជំនុំជម្រះដែលថា បញ្ហានៃទំនាក់ទំនងអំពីលក្ខខណ្ឌនៃជម្លោះប្រដាប់អាវុធ មិនត្រូវបានលើកឡើងដោយមេធាវីការពារក្តី នៅក្នុងសំណុំរឿងលេខ០០១ និងថាបើដូច្នេះ មិនមែន "នៅចំពោះមុខ [អង្គជំនុំជម្រះសាលាដំបូង] នោះ" គឺគ្មានមូលដ្ឋានឡើយ[15]។ ទោះបីជាមេធាវីការពារក្តីមិនជំទាស់ក៏ដោយ ក៏អង្គជំនុំជម្រះសាលាដំបូងមានការទទួលខុសត្រូវដោយឯករាជ្យ ដើម្បីធានាថា និយមន័យនៃឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិនៅក្នុងច្បាប់ អ.វ.ត.ក អនុវត្តទៅតាមគោលការណ៍នីត្យានុកូលភាព[16] ហើយការវិភាគដ៏ពិស្តាររបស់ខ្លួនអំពីឋានៈនៃលក្ខខណ្ឌតម្រូវស្តីពីទំនាក់ទំនងនៅក្នុងសាលក្រមសំណុំរឿងលេខ០០១ ឆ្លុះបញ្ចាំងពីការបំពេញប្រកបដោយសតិសម្បជញ្ញៈមួយលើការទទួលខុសត្រូវនេះ។

## ខ. និយមន័យនៃឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិនៅក្នុងច្បាប់ អវតក ស្របគ្នាទៅនឹងគោលការណ៍ស្តីពីនីត្យានុកូលភាព និងគួរតែត្រូវបានអនុវត្តដោយអង្គជំនុំជម្រះសាលាដំបូង

១៤- មាត្រា៥ នៃច្បាប់ អ.វ.ត.ក ចែងថា ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ គឺជា៖ "អំពើទាំងឡាយណាដែលបានប្រព្រឹត្តឡើងជាផ្នែកនៃការវាយប្រហារដ៏ទូលំទូលាយ ឬជាប្រព័ន្ធសំដៅប្រឆាំងទៅលើប្រជាជនស៊ីវិលណាមួយ ដោយមូលហេតុ ជាតិ នយោបាយ ជាតិពន្ធុ ពូជសាសន៍ ឬសាសនាណាមួយដូចជា៖

---

នៃការអនុវត្ត តុលាការកម្រងាកចេញពីសេចក្តីសម្រេចនានាពីមុនរបស់ខ្លួនណាស់អំពីចំណុចនានាទាក់ទងនឹងច្បាប់ ។ *សូមអាន* MOHAMED SHAHABUDDEEN, ករណីយុត្តិសាស្ត្រក្នុងតុលាការពិភពលោក (PRECEDENT IN THE WORLD COURT), 2-3 (2007) (ថ្លែងថា "ការពិតគឺថាតុលាការនានាស្វែងរកការណែនាំតាមរយៈសេចក្តីសម្រេចពីមុនៗរបស់ខ្លួនដោយពួកគាត់ចាត់ទុកសេចក្តីសម្រេចទាំងនោះថាជាសេចក្តីសម្រេចបញ្ចប់ដ៏គួរឲ្យទុកចិត្តបានអំពីច្បាប់ និងថាទោះបីជាខ្លួនមានអំណាចងាកចេញពីសេចក្តីសម្រេចទាំងនោះក៏ដោយ ក៏ពួកគាត់ទំនងជាមិនអនុវត្តអំណាចបែបនេះដែរ) ។ ស្រដៀងគ្នានេះដែរ អង្គជំនុំជម្រះសាលាឧទ្ធរណ៍នៃតុលាការ ICTY បានសម្រេចថា "វិធានធម្មតាគឺថា សេចក្តីសម្រេចនានាពីមុនគឺត្រូវបានគេអនុវត្តតាម ហើយការប្រាស់ចាកពីសេចក្តីសម្រេចទាំងនោះ គឺជាករណីលើកលែង" ។ *រដ្ឋអាជ្ញា ទល់នឹង Aleksovski*, សាលដីកា, សំណុំរឿងលេខ: IT-95-14/1-A, អង្គជំនុំជម្រះសាលាឧទ្ធរណ៍នៃតុលាការ ICTY, ២៤ មីនា ២០០០, កថាខណ្ឌទី១០៩ ។

[15]សូមមើលសាលដីកាលើបណ្តឹងឧទ្ធរណ៍របស់ អៀង ធីរិទ្ធ និង នួន ជា ប្រឆាំងនឹងដីកាដំណោះស្រាយ ចុះថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ២០១១, កថាខណ្ឌទី១៤៤ ។

[16] អង្គជំនុំជម្រះសាលាដំបូង បានទទួលស្គាល់ការទទួលខុសត្រូវនេះ នៅក្នុងសាលក្រមសំណុំរឿងលេខ ០០១ ដោយធ្វើការកត់សំគាល់ថា "ដោយមិនគិតថា កម្មវត្ថុនោះស្ថិតក្រោមយុត្តាធិការរបស់អង្គជំនុំជម្រះឡើយ បទឧក្រិដ្ឋកម្មដែលបានចោទប្រកាន់នីមួយៗ ហើយនិងទម្រង់នៃការទទួលខុសត្រូវ ត្រូវតែអនុលោមតាមគោលការណ៍នីត្យានុកូលភាពដែរ" ។ សាលក្រមសំណុំរឿងលេខ ០០១, កថាខណ្ឌទី ២៦ (លើកយោងមាត្រា៣៣(ថ្មី) នៃច្បាប់ អ.វ.ត.ក) ។ *សូមអានផងដែរ* វិធាន៩៨ នៃវិធានផ្ទៃក្នុង អ.វ.ត.ក ។ *រដ្ឋអាជ្ញា ទល់នឹង Vasilijevic*, សាលក្រមកាត់ក្តី, សំណុំរឿងលេខ: IT-98-32-T, ២៩ វិច្ឆិកា ២០០២, កថាខណ្ឌទី 198 (កត់សំគាល់ថា "អង្គជំនុំជម្រះសាលាដំបូងនីមួយៗ គឺមានកាតព្វកិច្ចធានាឲ្យប្រាកដថា ច្បាប់ដែលអនុវត្តចំពោះបទល្មើសព្រហ្មទណ្ឌណាមួយ ជាការពិតគឺជាច្បាប់ទម្លាប់") ។

ការធ្វើមនុស្សឃាត ការសម្លាប់រង្គាល ការធ្វើឱ្យទៅជាទាសករ ការនិរទេស ការដាក់ក្នុងមន្ទីរឃុំឃាំង ការធ្វើទារុណកម្ម ការរំលោភសេពសន្ថវៈ ការធ្វើទុក្ខបុកម្នេញដោយមូលហេតុ នយោបាយ ពូជសាសន៍ ឬសាសនា អំពើអមនុស្សធម៌ផ្សេងៗទៀត"[17]។ អ្វីដែលគួរឱ្យកត់សំគាល់នៅក្នុងមាត្រា៥ ពុំបាននិយាយយោងលើជម្លោះប្រដាប់អាវុធទេ ឬឧក្រិដ្ឋកម្មដទៃទៀតដែលជាប់ជំពាក់នឹងជម្លោះប្រដាប់អាវុធ ដូចជាឧក្រិដ្ឋកម្មសង្គ្រាម ឬឧក្រិដ្ឋកម្មប្រឆាំងនឹងសន្តិភាពនោះទេ។

១៥- ដើម្បីឱ្យអនុវត្តបាននៅ អ.វ.ត.ក និយមន័យនៃឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិនៅក្នុង មាត្រា៥ ត្រូវតែអនុលោមតាមបទដ្ឋានអន្តរជាតិស្តីពីភាពត្រឹមត្រូវយុត្តិធម៌ រួមទាំងគោលការណ៍នីត្យានុកូលភាព ដែលគោលការណ៍នេះការពារប្រឆាំងនឹងការអនុវត្តច្បាប់ប្រតិសកម្ម។ អនុវត្តទៅតាមបទដ្ឋាននេះ តម្រូវថា ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ដូចដែលបានឱ្យនិយមន័យនៅក្នុងមាត្រា ៥ នោះគឺ (១) ត្រូវបាន "ទទួលស្គាល់នៅក្រោមច្បាប់កម្ពុជា ឬអន្តរជាតិ នៅចន្លោះថ្ងៃទី ១៧ ខែមេសា ឆ្នាំ១៩៧៥ និងថ្ងៃទី៦ ខែមករា ឆ្នាំ១៩៧៩" និង (២)ត្រូវបានគេ "ព្យាករទុកជាមុនបានយ៉ាងគ្រប់គ្រាន់ និងថា ច្បាប់ដែលចែងអំពីការទទួលខុសត្រូវបែបនេះ អាចឱ្យជនជាប់ចោទរកបានយ៉ាងគ្រប់គ្រាន់ក្នុងពេលដែលពាក់ព័ន្ធ"[18]។

១៦- តាមការអនុវត្តការសាកល្បងនេះ បានបញ្ជាក់យ៉ាងច្បាស់ថានិយមន័យនៃឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិក្នុងមាត្រា៥ រួមទាំងកង្វះខាតនៃលក្ខខណ្ឌតម្រូវអំពីទំនាក់ទំនង គឺស្របគ្នានឹងគោលការណ៍នីត្យានុកូលភាព។ ដូចបានលើកមកពិភាក្សាខាងក្រោមនេះ គឺថា (ក)គ្មានលក្ខខណ្ឌអំពីទំនាក់ទំនងនៃជម្លោះប្រដាប់អាវុធ កើតមានឡើងនៅក្នុងច្បាប់ទំនៀមទម្លាប់អន្តរជាតិ នៅក្នុងអឡុងពេលនៃយុត្តាធិការពេលវេលារបស់ អ.វ.ត.ក ទេ និង (ខ)ជនជាប់ចោទអាចព្យាករទុកជាមុន និងអាចរកបាន ថាពួកគេអាចនឹងត្រូវបានដាក់ឱ្យទទួលខុសត្រូវចំពោះឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ដែលបានប្រព្រឹត្តឡើងនៅក្នុងប្រទេសកម្ពុជា ក្រៅជម្លោះប្រដាប់អាវុធ។

## ក. លក្ខខណ្ឌដែលតម្រូវឱ្យមានទំនាក់ទំនងគ្នាជាមួយនឹងជម្លោះប្រដាប់អាវុធ ក្នុងយុត្តាធិការពេលវេលារបស់ អវតក គឺគ្មានអត្ថិភាពនៅក្នុងច្បាប់ទំនៀមទម្លាប់អន្តរជាតិទេ

[17] មាត្រា៥ នៃច្បាប់ស្តីពីការបង្កើតឱ្យមានអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ដើម្បីកាត់សេចក្តីឧក្រិដ្ឋកម្មដែលប្រព្រឹត្តឡើងនៅក្នុងរយៈកាលនៃកម្ពុជាប្រជាធិបតេយ្យ, ចុះថ្ងៃទី២៧ តុលា ២០០៤ ។

[18] *សូមអាន* សាលក្រមសំណុំរឿងលេខ០០១ កថាខណ្ឌទី២៨-២៩។ សាលដីការបស់ អបជ, ចុះថ្ងៃទី១៥ កុម្ភៈ ២០១១, លើបណ្តឹងឧទ្ធរណ៍របស់របស់ នួន ជា និង អៀង ធីរិទ្ធ ប្រឆាំងនឹងដីកាដំណោះស្រាយ, កថាខណ្ឌទី ១០៥-១០៦។

១៧- មានការទទួលស្គាល់យ៉ាងទូលំទូលាយថា នៅក្នុងច្បាប់ទំនៀមទម្លាប់អន្តរជាតិបច្ចុប្បន្ននេះ គឺមិនតម្រូវឱ្យអំពើជាដើមអាទិ៍ទាំងឡាយនៃឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ត្រូវតែមានទំនាក់ទំនងជាមួយនឹងជម្លោះប្រដាប់អាវុធនោះឡើយ។ ចំណុចនេះ គឺត្រូវបានឆ្លុះបញ្ចាំងឱ្យឃើញនៅក្នុងយុត្តិសាស្ត្ររបស់តុលាការពិសេសនានា ក៏ដូចជានៅក្នុងលក្ខន្តិកៈទីក្រុងរ៉ូមរបស់តុលាការព្រហ្មទណ្ឌអន្តរជាតិ[19]។ ហេតុនេះ បញ្ហាដែលពាក់ព័ន្ធនៅទីនេះ គឺមិនមែនអំពីថាតើលក្ខខណ្ឌតម្រូវទំនាក់ទំនងណាមួយមានអត្ថិភាព ឬមិនមាននៅក្នុងពេលបច្ចុប្បន្ននេះនោះទេ តែផ្ទុយទៅវិញ គឺអំពីថាតើលក្ខខណ្ឌដែលតម្រូវឱ្យមានទំនាក់ទំនងគ្នាដែលមានអត្ថិភាពនោះ មានអត្ថិភាពមែនដែរ ឬយ៉ាងណា នៅក្នុងអម្លុងពេលវេលាដែលទាក់ទងនឹងរឿងក្តីនេះ *គឺបាននិយថា* ចាប់តាំងពីឆ្នាំ១៩៧៥ ដល់ឆ្នាំ១៩៧៩។

១៨- អង្គបុរេជំនុំជម្រះបានកំណត់ថា និយមន័យនៃឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិនៅក្នុងអម្លុងពេលពីឆ្នាំ១៩៧៥ ដល់ឆ្នាំ១៩៧៩ ដែលលប់លើគេនោះ គឺជានិយមន័យដែលបានឆ្លុះបញ្ចាំងនៅក្នុងធម្មនុញ្ញរបស់តុលាការអន្តរជាតិនាទីក្រុងនូរ៉ាំប៊ឺហ្គឆ្នាំ១៩៤៥ ("IMT Charter") និងនៅក្នុងសេចក្តីសម្រេចចិត្តឆ្នាំ១៩៤៦ របស់មហាសន្និបាតអង្គការសហប្រជាជាតិបានបញ្ជាក់អះអាងពីគោលការណ៍នានា ដែលត្រូវបានទទួលស្គាល់ដោយធម្មនុញ្ញតុលាការអន្តរជាតិនាទីក្រុងនូរ៉ាំប៊ឺហ្គ[20]។ មាត្រា៦.គ នៃធម្មនុញ្ញតុលាការអន្តរជាតិនាទីក្រុងនូរ៉ាំប៊ឺហ្គ បានចែងអំពីការទទួលខុសត្រូវខាងព្រហ្មទណ្ឌជាបុគ្គល ចំពោះឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ "គឺបាននិយថា អំពើមនុស្សឃាត ការសម្លាប់រង្គាល ការធ្វើឱ្យទៅជាទាសករ ការនិរទេស និងអំពើអមនុស្សធម៌ផ្សេងៗទៀតដែលត្រូវបានប្រព្រឹត្តទៅលើប្រជាជនជនស៊ីវិលនៅមុនពេល ឬនៅក្នុងពេលសង្គ្រាម ឬការធ្វើទុក្ខបុកម្នេញផ្សេងៗ ដោយសារមូលហេតុខាងនយោបាយ ពូជសាសន៍ ឬសាសនា ដោយការអនុវត្ត ឬដោយជាប់ទាក់ទងគ្នាទៅនឹងឧក្រិដ្ឋកម្មណាមួយ ដែលស្ថិតនៅក្នុងវង្វង់យុត្តាធិការរបស់តុលាការ ទោះជាការរំលោភ ឬមិនរំលោភទៅលើច្បាប់របស់ប្រទេស ដែល

[19] *សូមអាន* សាលក្រមសំណុំរឿងលេខ០០១, កថាខណ្ឌទី២៩១-២៩២ ("សញ្ញាណនៃជម្លោះប្រដាប់អាវុធ ...មិនបានបង្កើតជាផ្នែកនិយមន័យនៅក្នុងទម្លាប់បច្ចុប្បន្ននៃឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិឡើយ")។ លក្ខន្តិកៈនៃទីក្រុងរ៉ូមរបស់តុលាការព្រហ្មទណ្ឌអន្តរជាតិ, ឯកសារ U.N. Doc. A/CONF.183/9, ចុះថ្ងៃទី១៧ កក្កដា ១៩៩៨, មាត្រា៧.១.ក-ដ (គ្មានលក្ខខណ្ឌដែលតម្រូវឱ្យមានទំនាក់ទំនងទៅវិញទៅមកសម្រាប់ឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិនោះទេ)។ សាលក្រម *នៃករណីរឿងក្តីរបស់ រដ្ឋអាជ្ញា ទល់នឹង Akayesu*, សំណុំរឿងលេខ ICTR-96-4-T, អង្គជំនុំជម្រះសាលាដំបូងនៃតុលាការ ICTR, ថ្ងៃទី២ កញ្ញា ១៩៩៨, កថាខណ្ឌទី៥៦៥ ("ឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិត្រូវបាន...ហាមឃាត់ទោះបីជាត្រូវបានប្រព្រឹត្តនៅក្នុងជម្លោះប្រដាប់អាវុធ ដែលមានលក្ខណៈអន្តរជាតិឬផ្ទៃក្នុងក៏ដោយ")។

[20] សាលដីការបស់អបជ, ចុះថ្ងៃទី១៥ កុម្ភៈ ២០១១, លើបណ្តឹងឧទ្ធរណ៍របស់របស់ នួន ជា និង អៀង ធីរិទ្ធ ប្រឆាំងនឹងដីកាដំណោះស្រាយ, កថាខណ្ឌទី១៤៤។

ជាទីកន្លែងដែលឧក្រិដ្ឋកម្មត្រូវបានប្រព្រឹត្តក៏ដោយ”[21]។ ការដាក់បញ្ចូលនូវប្រយោគ “ដោយមានទំនាក់ទំនងជាមួយនឹងឧក្រិដ្ឋកម្មណាមួយ ដែលស្ថិតនៅក្នុងវង្វង់យុត្តាធិការរបស់តុលាការ” ត្រូវបានគេយល់មានន័យថា ឧក្រិដ្ឋកម្មនានានៅក្នុង មាត្រា៦.គ តែងតែត្រូវបានប្រព្រឹត្តនៅក្នុងបរិបទនៃជម្លោះប្រដាប់អាវុធ ឬការកាន់កាប់ដោយយោធាណាមួយ ព្រោះដោយសារ “ឧក្រិដ្ឋកម្មផ្សេងៗទៀតដែលស្ថិតនៅក្នុងវង្វង់យុត្តាធិការរបស់តុលាការ”-ឧក្រិដ្ឋកម្មសង្គ្រាម និងឧក្រិដ្ឋកម្មប្រឆាំងនឹងសន្តិភាព *តាមជាក់ស្តែង* សុទ្ធតែជាប់ទាក់ទងគ្នាទៅនឹងសង្គ្រាម[22]។

១៩- ក៏ប៉ុន្តែ ដូចដែលសហព្រះរាជអាជ្ញាបានលើកយកមកជជែកតវ៉ារួចហើយនៅក្នុងសេចក្តីសន្និដ្ឋានកាលពីមុនៗថា លក្ខខណ្ឌតម្រូវឲ្យមានទំនាក់ទំនងគ្នា ដែលមាននៅក្នុងធម្មនុញ្ញតុលាការអន្តរជាតិនាទីក្រុងនូរ៉ាំប៊ឺហ្គនោះ គឺវាគ្រាន់តែជាការកម្រិតមួយផ្នែកយុត្តាធិការតែប៉ុណ្ណោះ មិនមែនជាការដាក់កម្រិតដែល មានជាប់មកជាមួយស្រាប់ទៅលើវិសាលភាពនៃឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិដែលស្ថិតនៅក្រោមច្បាប់អន្តរជាតិនោះឡើយ[23]។ តុលាការអន្តរជាតិនានា បានទទួលស្គាល់ថា “ទំនាក់ទំនងគ្នាដែលនៅក្នុងធម្មនុញ្ញនៃទីក្រុងនូរ៉ាំប៊ឺហ្គ រវាងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ និងឧក្រិដ្ឋកម្មពីរប្រភេទផ្សេងទៀត គឺឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ និងឧក្រិដ្ឋកម្មសង្គ្រាម ជា*លក្ខណៈពិសេសដោយឡែក* សម្រាប់បរិបទនៃសវនាការជំនុំជម្រះក្តីនៅតុលាការទីក្រុងនូរ៉ាំប៊ឺហ្គ ដែលត្រូវបានបង្កើតឡើងជាក់លាក់សម្រាប់តែ “ធ្វើការជំនុំជម្រះក្តីឲ្យបានប្រកបដោយត្រឹមត្រូវយុត្តិធម៌ និងដោយឆាប់រហ័ស និងធ្វើការផ្តន្ទាទោសចំពោះឧក្រិដ្ឋជនសង្គ្រាមសំខាន់ៗរបស់បណ្តាប្រទេសក្នុងបក្សសម្ព័ន្ធយោធានៅទ្វីបអឺរ៉ុប”ប៉ុណ្ណោះ[24]។ ជាការ

[21] កិច្ចព្រមព្រៀងដើម្បីធ្វើការកាត់ទោស និងផ្តន្ទាទោសឧក្រិដ្ឋជនសង្គ្រាមសំខាន់ៗនៃប្រទេសមហាអំណាចនៅក្នុងបក្សសម្ព័ន្ធយោធានៃទ្វីបអឺរ៉ុប និង ធម្មនុញ្ញរបស់តុលាការសឹកអន្តរជាតិ, ចុះថ្ងៃទី៨ សីហា ១៩៤៥, ឯកសារលេខ 82 U.N.T.S.279, មាត្រា៦.គ [ដែលជាបន្តមកទៀតនៅក្នុងនេះហៅថា“IMT Charter”] (ដែលនិយាយថា ឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិត្រូវតែអនុវត្ត “ស្របទៅតាម ឬ ដោយមានការទាក់ទងគ្នាទៅនឹងឧក្រិដ្ឋកម្មដែលស្ថិតនៅក្នុងយុត្តាធិការរបស់តុលាការ)។ ឯកសារលេខ U.N.G.A. Res95 (1), ចុះថ្ងៃទី ១១ ធ្នូ ១៩៤៦។

[22] *សូមអាន* សៀវភៅរបស់លោក MATTRAUX ដែលមានចំណងជើងថា ឧក្រិដ្ឋកម្មអន្តរជាតិនិងតុលាការពិសេសនានា (ឆ្នាំ២០០៥), ត្រង់ទំព័រ១៥៩។

[23] *សូមអាន* ចម្លើយតបរួមរបស់សហព្រះរាជអាជ្ញា, កថាខណ្ឌទី១៨១។

[24] *ករណីរឿងក្តីរបស់ រដ្ឋអាជ្ញា ទល់នឹង* Tadić, សេចក្តីសម្រេចលើញត្តិស្នើសុំរបស់មេធាវីការពារក្តីស្តីពីយុត្តាធិការ, សំណុំរឿងលេខ IT-94-I-T, អង្គជំនុំជម្រះសាលាដំបូងទី II នៃតុលាការ ICTY, ចុះថ្ងៃទី១០ សីហា ១៩៩៥, កថាខណ្ឌទី៧៨ (“ដែលដកស្រង់ខ្លឹមសារមាត្រា១ នៃ IMT Charter”) (ការសង្កត់ន័យបន្ថែមដោយអក្សរទ្រេត)។ *ករណីរឿងក្តីរបស់ រដ្ឋអាជ្ញា ទល់នឹង* Tadić, សេចក្តីសម្រេចលើញត្តិស្នើសុំរបស់មេធាវីការពារក្តីស្តីពីបណ្តឹងឧទ្ធរណ៍លើបញ្ហាបន្ទាន់បង្ខំ ស្តីពីយុត្តាធិការ, សំណុំរឿងលេខ IT-94-I-T, អង្គជំនុំជម្រះសាលាឧទ្ធរណ៍នៃតុលាការ ICTY, ចុះថ្ងៃទី២ តុលា ១៩៩៥, [ដែលជាបន្តមកទៀតនៅក្នុងនេះហៅថា“សេចក្តីសម្រេចលើបណ្តឹងឧទ្ធរណ៍ស្តីពីយុត្តាធិការករណីTadić”], កថាខណ្ឌទី ១៤០ (ដែលយល់ស្របថាលក្ខខណ្ឌតម្រូវឲ្យមានទំនាក់ទំនងគ្នាទៅវិញទៅមករបស់ IMTCharter គឺជាលក្ខណៈពិសេសសម្រាប់យុត្តាធិការនៃតុលាការទីក្រុងនូរ៉ាំប៊ឺហ្គ ហើយដែលចែងថា “ មិនមានមូលដ្ឋានខាងតក្កវិជ្ជា ឬខាងអង្គច្បាប់សម្រាប់លក្ខខណ្ឌ

គួរឱ្យកត់សំគាល់ សេចក្តីយោងទៅលើពាក្យ “នៅមុនពេល ឬក្នុងពេលសង្គ្រាម” ដែលចែងក្នុងមាត្រា ៦.គ បានឱ្យដឹងថា សញ្ញាណនៃឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ គឺមិនត្រូវបានកំណត់ដូចដែលមានជាប់មកជាមួយស្រាប់ ដែលតម្រូវឱ្យមានតែក្នុងរង្វង់នៃពាក្យ ក្នុងអម្លុងពេលនៃសង្គ្រាមនោះឡើយ[25]។ លើសពីនេះ ពាក្យពេចន៍ដែលប្រើនៅក្នុងសាលក្រមតុលាការទីក្រុងនូរ៉ាំប៊ឺហ្គផ្ទាល់ គឺគាំទ្រចំពោះសញ្ញាណដែលថា លក្ខខណ្ឌដែលតម្រូវឱ្យមានទំនាក់ទំនងគ្នារវាងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ និងឧក្រិដ្ឋកម្មសង្គ្រាម ឬឧក្រិដ្ឋកម្មប្រឆាំងនឹងសន្តិភាព គឺជាយុត្តាធិការដែលជាក់លាក់សម្រាប់ធម្មនុញ្ញតុលាការអន្តរជាតិនាទីក្រុងនូរ៉ាំប៊ឺហ្គ ដោយហេតុថាគេបានធ្វើសេចក្តីយោងដល់ “ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ *នៅក្នុងនិយមន័យនៃធម្មនុញ្ញនោះ*”[26]។

២០- ចំពោះការប្រកាន់ទស្សនទានស្តីពីឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ នៅក្នុងប៉ុន្មានឆ្នាំកន្លង ទៅបន្ទាប់ពីធម្មនុញ្ញតុលាការអន្តរជាតិនាទីក្រុងនូរ៉ាំប៊ឺហ្គ គឺជាការបង្ហាញឱ្យឃើញថែមទៀតថាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ បានមានអត្ថិភាពក្នុងនាមជាទស្សនទានមួយដែលផ្សេងពីជម្លោះប្រដាប់អាវុធ ដែលស្ថិតនៅក្រោមច្បាប់ទំនៀមទម្លាប់អន្តរជាតិមុនឆ្នាំ១៩៧៥[27]។ ឧទាហរណ៍ដូចជា ច្បាប់លេខ១០ របស់ក្រុមប្រឹក្សាត្រួតពិនិត្យឆ្នាំ១៩៤៥ (“CCL10”) ដែលបានអនុម័ត ដោយប្រទេសមហាអំណាចនានាខាងសម្ព័ន្ធមិត្តសឹងតែនៅក្នុងពេលភ្លាមៗ បន្ទាប់ពីការប្រកាសឱ្យប្រើធម្មនុញ្ញតុលាការអន្តរជាតិនាទីក្រុងនូរ៉ាំប៊ឺហ្គ បានចែងពីការកាត់ទោស លើបទឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ អនុលោមទៅតាមនិយមន័យ ដែលក្នុង

---

តម្រូវនេះឡើយ ហើយលក្ខខណ្ឌតម្រូវដូចនេះត្រូវបានគេបោះបង់ចោលនៅក្នុងការអនុវត្តរបស់រដ្ឋ ជាបន្ត បន្ទាប់មកទៀតទាក់ទងនឹងឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ”។)

[25] IMT Charter, មាត្រា ៦.គ។

[26] *ករណីរឿងក្តីរបស់ សហរដ្ឋអាមេរិក ទល់នឹង Herman Goering*, ដីកាបញ្ជូនរឿងទៅជំនុំជម្រះនិងសាលក្រម, ដែលត្រូវបាន*បោះពុម្ពឡើងវិញនៅក្នុង*ពេលសវនាការជំនុំជម្រះក្តីនៃឧក្រិដ្ឋជនសង្គ្រាមសំខាន់ៗនៅចំពោះមុខតុលាការសឹកអន្តរជាតិ, ឆ្នាំ១៩៤៨ (សង្កត់ន័យបន្ថែមដោយ*អក្សរទ្រេត*) ។

[27] *សូមអាន* សាលក្រមនៃសំណុំរឿងលេខ០០១, កថាខណ្ឌទី២៩១។ សហព្រះរាជអាជ្ញាសូមជូនសេចក្តីសន្និដ្ឋានថា គោលការណ៍នៃតុលាការក្រុងនូរ៉ាំប៊ឺហ្គ ដែលបានអនុម័តដោយមហាសន្និបាត អសប ក្នុងឆ្នាំ១៩៤៦, គឺតំណាងឱ្យការបញ្ជាក់អះអាងជាទូទៅមួយនៃ IMT Charter និងការកាត់ទោសចំពោះបុគ្គលទាំងឡាយពីបទឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិនៅឯតុលាការទីក្រុងនូរ៉ាំប៊ឺហ្គ តែមិនបានធ្វើការសម្រេចជាស្ថាពរអំពីបញ្ហាថា តើនៅពេលនោះលក្ខខណ្ឌដែលតម្រូវឱ្យមានទំនាក់ទំនងគ្នាទៅវិញទៅមកត្រូវបានទាមទារឱ្យមានដែរឬទេក្រោមច្បាប់ទម្លាប់អន្តរជាតិ? ជាពិសេសផ្អែកលើស្មារតីនៃព្រឹត្តិហេតុនានានៅក្នុងសហសម័យដូចជាការអភិវឌ្ឍន៍របស់អង្គនៃយុត្តិសាស្ត្រដែលសម្រាប់ពង្រឹងការអនុវត្តន៍ច្បាប់លេខ១០ របស់ក្រុមប្រឹក្សាត្រួតពិនិត្យ ។ *សូមអាន* សេចក្តីសម្រេចរបស់មហាសន្និបាត អសប លេខ Res.95 (1), U.N GAOR U.N. Doc. A/64/Add.1(1946), ទំព័រ ១៨៨។

នោះមិនមានការតភ្ជាប់គ្នាជាមួយនឹងជម្លោះប្រដាប់អាវុធទេ[28]។ អវត្តមាននូវលក្ខខណ្ឌតម្រូវឱ្យមានទំនាក់ទំនងគ្នា នៅក្នុងច្បាប់លេខ១០ របស់ក្រុមប្រឹក្សាត្រួតពិនិត្យឆ្នាំ១៩៤៥ បានអនុញ្ញាតឱ្យមានចំណាត់ថ្នាក់នៃការកាត់សេចក្តីចំពោះឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិមួយ កាន់តែទូលំទូលាយជាងនៅក្នុងមាត្រា ៦.គ នៃធម្មនុញ្ញតុលាការអន្តរជាតិនាទីក្រុងនូរ៉ាំប៊ឺហ្គ បានអនុញ្ញាតទៅទៀត[29]។ ឧទាហរណ៍ដូចជា នៅក្នុងករណីរឿងក្តីរបស់ *សហរដ្ឋអាមេរិក ទល់នឹង* Ohlendorf *និងគូកន*, តុលាការសឹក ស.រ.អ បានថ្លែងថា អវត្តមាននៃលក្ខខណ្ឌដែលតម្រូវឱ្យមានទំនាក់ ទំនងដូចនៅក្នុងច្បាប់ក្រុមប្រឹក្សាត្រួតពិនិត្យលេខ១០ បានបើកឱ្យធ្វើការកាត់ទោសលើឧក្រិដ្ឋកម្មនានា ដែលបានប្រព្រឹត្តមិនមែននៅក្នុងពេលសង្គ្រាមដែលរួមមាន "រាលឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិនានា ទាំងអស់ឱ្យបានដឹង និងយល់ថា ស្ថិតនៅក្រោមគោលការណ៍ទូទៅនៃច្បាប់ព្រហ្មទណ្ឌ"[30]។ នៅក្នុងករណីរឿងក្តីរបស់ *សហរដ្ឋអាមេរិក ទល់នឹង* Ohlendorf *និងគូកន*, តុលាការសឹក ស.រ.អ បានពន្យល់ថាពួកអ្នករៀបចំពង្រាងច្បាប់លេខ១០ របស់ក្រុមប្រឹក្សាត្រួតពិនិត្យឆ្នាំ១៩៤៥ បានមានបំណងចង់ដក ចេញនូវវាក្យខណ្ឌដែលចែងថា "ដោយអនុវត្ត ឬដោយមានទំនាក់ទំនងជាមួយនឹងវាក្យខណ្ឌណាមួយដែលស្ថិតនៅក្នុងវង្វង់យុត្តាធិការរបស់តុលាការ"ដែលឃើញមាននៅក្នុងមាត្រា៦.គ នៃធម្មនុញ្ញតុលាការអន្តរជាតិនាទីក្រុងនូរ៉ាំប៊ឺហ្គ[31]។ ស្រដៀងគ្នានេះដែរ មានអ្នកធ្វើសេចក្តីអធិប្បាយផ្តល់មតិផ្នែកច្បាប់លេចធ្លោជាង

---

[28] ច្បាប់លេខ១០ របស់ក្រុមប្រឹក្សាត្រួតពិនិត្យ, ស្តីពីការផ្តន្ទាទោសចំពោះជនទាំងឡាយដែលមានទោសពីបទឧក្រិដ្ឋកម្មសង្គ្រាម, ឧក្រិដ្ឋកម្មប្រឆាំងនឹងសន្តិភាព, ឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ, ចុះថ្ងៃទី២០ ធ្នូ ១៩៤៥ ដែលពីពេលនេះតទៅហៅថា "ច្បាប់ក្រុមប្រឹក្សាត្រួតពិនិត្យលេខ ១០"។

[29] ប្រការដែលបញ្ញត្តិនៃច្បាប់លេខ១០ ស្តីពីឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិមានការរិតត្បិតតិចជាង IMT Charter គឺជាការធ្វើឱ្យមានអត្ថន័យដោយផ្អែកលើស្មារតីនៃប្រការដែលថា តុលាការទីក្រុងនូរ៉ាំប៊ឺហ្គត្រូវបានបង្កើតឡើងដើម្បីជំនុំជម្រះក្តីចំពោះចារីទាំងឡាយដែលធ្ងន់ធ្ងរបំផុតដែលមានចំនួនកម្រិតកំណត់ ចំណែកឯតុលាការសឹកនានាវិញយកច្បាប់លេខ១០មកអនុវត្ត ដែលត្រូវបានគេរំពឹងទុកថា ដើម្បីជំនុំជម្រះក្តីចំពោះចំណាត់ថ្នាក់នៃចារីដែលមានចំនួនច្រើនជាងនេះឆ្ងាយណាស់។

[30] *ករណីរឿងក្តីរបស់សហរដ្ឋអាមេរិក ទល់នឹង Ohlendorf និងគូកន ("ករណីរឿងក្តីរបស់ Einsatzgruppen")* ,នៅក្នុងសវនាការជំនុំជម្រះក្តីលើឧក្រិដ្ឋជនសង្គ្រាមចំនួន៤លើក នៅចំពោះមុខតុលាការសឹកនៃទីក្រុងនូរ៉ាំប៊ឺហ្គ ក្រោមច្បាប់លេខ១០របស់ក្រុមប្រឹក្សាត្រួតពិនិត្យ, ត្រង់ទំព័រ ៤៩៩ (ឆ្នាំ១៩៥០) ។

[31] *ករណីរឿងក្តីរបស់ សហរដ្ឋអាមេរិក ទល់នឹង Alstoetter ("ករណីរឿងក្តីស្តីពីបញ្ញាយុត្តិធម៌")* , នៅក្នុងសវនាការជំនុំជម្រះក្តីលើឧក្រិដ្ឋជនសង្គ្រាមចំនួន៣លើក នៅចំពោះមុខតុលាការសឹកនៃទីក្រុងនូរ៉ាំប៊ឺហ្គ ក្រោមច្បាប់លេខ១០របស់ក្រុមប្រឹក្សាត្រួតពិនិត្យ, ត្រង់ទំព័រ៩៧៤ (ឆ្នាំ១៩៥១) (ដែលពន្យល់ថា ច្បាប់លេខ១០របស់ក្រុមប្រឹក្សាត្រួតពិនិត្យ គឺខុសគ្នាពីធម្មនុញ្ញ (Charter)។ ធម្មនុញ្ញនេះឱ្យនិយមន័យឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិថា ជាអំពើអមនុស្សធម៌ ជាដើម។ល។...ដែលបានប្រព្រឹត្ត "ដោយអនុវត្តតាម ឬដោយជាប់ទាក់ទងគ្នាទៅនឹង ឧក្រិដ្ឋកម្មណាមួយដែលស្ថិតនៅក្នុងយុត្តាធិការរបស់តុលាការ" ចំណែកឯនៅក្នុងច្បាប់លេខ១០របស់ក្រុមប្រឹក្សាត្រួតពិនិត្យវិញពាក្យពេជន៍ចុងក្រោយបង្អស់ដែលបានដកស្រង់ គឺត្រូវបានគេបំភ្លេចចេញពីក្នុងនិយមន័យដោយចេតនា")។ *ប៉ុន្តែសូមអាន ករណីរឿងក្តីរបស់សហរដ្ឋអាមេរិក ទល់នឹង Flick និងគូកន ("ករណីរឿក្តីរបស់ Flick")*, នៅក្នុងសវនាការជំនុំជម្រះក្តីលើឧក្រិដ្ឋជនសង្គ្រាមចំនួន៦លើក នៅចំពោះមុខតុលាការ សឹកនៃទីក្រុងនូរ៉ាំប៊ឺហ្គ ក្រោមច្បាប់លេខ១០របស់ក្រុមប្រឹក្សាត្រួតពិនិត្យ, ត្រង់ទំព័រ១២១២-១៣ (ឆ្នាំ១៩៥២) (ដែលរកឃើញថា "គ្មានការគាំទ្រ"

គេមួយរូប ដែលសរសេរនៅក្នុងឆ្នាំ១៩៤៦ ថា "យុត្តាធិការទាំងមូលដែលបានវិវឌ្ឍ នៅក្នុងដំណើរការនីតិវិធីនៅតុលាការក្រុងនូរ៉ាំប៊ឺហ្គ ដែលសំដៅចង់ដាក់កម្រិតចំពោះឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ដល់ឧក្រិដ្ឋកម្មទាំងឡាយដូចនេះ ដែលទាក់ទងទៅនឹងសង្គ្រាម បានជាប់ពាក់ព័ន្ធនឹងតុលាការនានាដែលជាអ្នកដោះស្រាយលើបទឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ក្រោមច្បាប់លេខ១០របស់ក្រុមប្រឹក្សាត្រួតពិនិត្យឆ្នាំ១៩៤៥ ទៅវិញ"[32]។

២១- ចំពោះតម្លៃដែលអាចធ្វើឱ្យជឿតាមនៃច្បាប់លេខ១០ របស់ក្រុមប្រឹក្សាត្រួតពិនិត្យវិញ សហព្រះរាជអាជ្ញា បានធ្វើការកត់សំគាល់ថា នៅក្នុងសេចក្តីសម្រេចរបស់អង្គបុរេជំនុំជម្រះ លើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយរបស់ អៀង សារី អង្គជំនុំជម្រះនេះហាក់ដូចជាបានផ្តល់ឱ្យនូវទម្ងន់ដែលមានកម្រិតដល់ការដែលគ្មានលក្ខខណ្ឌ ដែលតម្រូវឱ្យមានទំនាក់ទំនងគ្នា ដូចដែលមាននៅក្នុងច្បាប់លេខ ១០ របស់ក្រុមប្រឹក្សាត្រួតពិនិត្យ ដោយផ្អែកលើមូលដ្ឋានថា "ជាសំខាន់បំផុត គឺមកពីវាជាច្បាប់ក្នុងស្រុក"[33]។ ប៉ុន្តែនៅក្នុងសេចក្តីសម្រេចរបស់ អបជ លើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយរបស់ អៀង ធីរិទ្ធ និង នួន ជា វិញ គឺអង្គជំនុំជម្រះនេះបានយល់ស្របថា ច្បាប់លេខ១០ របស់ក្រុមប្រឹក្សាត្រួតពិនិត្យ គឺជាភ័ស្តុតាងដែលទាក់ទងនៃ "និយមន័យ និងធាតុផ្សំបទល្មើសនៃឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ"[34]។ អង្គបុរេជំនុំជម្រះបានធ្វើការកត់សំគាល់នៅកន្លែងផ្សេងទៀតថា ច្បាប់លេខ១០ របស់ក្រុមប្រឹក្សាត្រួតពិនិត្យ គឺជាច្បាប់មួយ "ដែលឆ្លុះបញ្ចាំងឱ្យឃើញពី<u>ការព្រមព្រៀងគ្នាជាអន្តរជាតិ</u> រវាងបណ្តាប្រទេសមហាអំណាច <u>លើច្បាប់ជាធរមាន សម្រាប់ឧក្រិដ្ឋកម្មអន្តរជាតិនានា</u> និងយុត្តាធិការរបស់តុលាការសឹក ដែលត្រូវបានគេអំពាវនាវរក ដើម្បីឱ្យមកជួយធ្វើការសម្រេចសេចក្តីលើ

---

ចំពោះទឡ្ហីករណ៍ដែលលើកឡើងថា "ការបំភ្លេចចោលនូវពាក្យ[ទំនាក់ទំនងគ្នាទៅវិញទៅមក (nexus)] ពីក្នុងច្បាប់លេខ១០របស់ក្រុមប្រឹក្សាត្រួតពិនិត្យជាការបង្ហាញភស្តុតាងឱ្យឃើញអំពីចេតនាដែលចង់ពង្រីកយុត្តាធិការរបស់តុលាការថែមទៀត") ។

[32] សៀវភៅរបស់លោក Egon Schwelb,ដែលមានចំណងជើងថា *ឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ,* ដែលបោះផ្សាយដោយ 23 BRIT.Y.B OF INT'L L 178, 218 (ឆ្នាំ១៩៤៦)។ *សូមអានផងដែរនូវ* វិចារណកថារបស់លោក Theodore Meron, Theodor Meron, អំពីឧក្រិដ្ឋកម្មសង្គ្រាមនៅប្រទេសយូហ្គោស្លាវី និងការអភិវឌ្ឍន៍នៃច្បាប់អន្តរជាតិ, ដែលបោះផ្សាយដោយ 88 AM.J. INT'L L. 78, 85 (ឆ្នាំ១៩៩៤) (ដែលធ្វើសេចក្តីសន្និដ្ឋានថាក្រោមច្បាប់លេខ១០របស់ក្រុមប្រឹក្សាត្រួតពិនិត្យ "បានលប់ចោលនូវទំនាក់ទំនងគ្នាទៅវិញទៅមកផ្នែកយុត្តាធិការរវាងឧក្រិដ្ឋកម្មសង្គ្រាមនិងឧក្រិដ្ឋកម្មប្រឆាំងនឹងសន្តិភាព..[ត្បិតយ៉ាងដូចជា]ទំនាក់ទំនងនៃឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិគឺមានអត្ថិភាព ដោយឯករាជ្យពីសង្គ្រាម")។

[33] សាលដីការបស់អង្គបុរេជំនុំជម្រះលើបណ្តឹងឧទ្ធរណ៍របស់ អៀង សារី ប្រឆាំងនឹងដីកាដំណោះស្រាយ, ចុះថ្ងៃទី១១ មេសា ២០១១, កថាខណ្ឌទី ៣០៩។

[34] សាលដីការបស់ អបជ, ចុះថ្ងៃទី១៥ កុម្ភៈ ២០១១, លើបណ្តឹងឧទ្ធរណ៍របស់ នួន ជា និង អៀង ធីរិទ្ធ ប្រឆាំងនឹងដីកាដំណោះស្រាយ, កថាខណ្ឌទី ១៣០។

ឧក្រិដ្ឋកម្មទាំងនេះ”[35]។ តាមការពិត តុលាការព្រហ្មទណ្ឌអន្តរជាតិនានា និងអ្នកធ្វើសេចក្តីអធិប្បាយផ្តល់មតិផ្នែកច្បាប់ទាំងឡាយ ជាញឹកញយតែងតែពឹងផ្អែកលើច្បាប់លេខ១០របស់ក្រុមប្រឹក្សាត្រួតពិនិត្យ ឆ្នាំ១៩៤៥ ដើម្បីយកធ្វើជាភស្តុតាងបង្ហាញអំពីច្បាប់ទម្លាប់អន្តរជាតិ”[36]។

២២- លើសពីនេះ ប្រការដែលមានអនុសញ្ញាអន្តរជាតិចំនួន២ ត្រូវបានអនុម័តនៅមុនឆ្នាំ១៩៧៥ ដែលបានចែងកំណត់និយមន័យនៃឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិជាបុគ្គល ដែលមិនមានទំនាក់ទំនងគ្នាជាមួយជម្លោះប្រដាប់អាវុធណាមួយនោះ គឺជាការបញ្ជាក់ឲ្យដឹងយ៉ាងច្បាស់ថា ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិមិនមែនជាការជាប់គ្នាយ៉ាងជិតស្និទ្ធដែលមិនអាចបំបែកចេញពីគ្នាបានពីជម្លោះប្រដាប់អាវុធ នៅក្នុងអម្លុងនៃរបបកម្ពុជាប្រជាធិតេយ្យនោះឡើយ[37]។ នៅក្នុងឆ្នាំ១៩៤៨ អំពើប្រល័យពូជសាសន៍ដែលជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិមួយ ត្រូវបានរៀបចំចងក្រងឲ្យទៅជាក្រម ដែលមិនមានលក្ខខណ្ឌតម្រូវឲ្យមានទំនាក់ទំនងគ្នាជាមួយជម្លោះប្រដាប់អាវុធនោះទេ[38]។ បន្ទាប់មកទៀត នៅក្នុង ឆ្នាំ១៩៧៣ ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិនៃរបបអាប៉ាថេត ត្រូវបានកំណត់និយមន័យ ដោយមិនបានយោងទៅលើធម្មនុញ្ញតុលាការអន្តរជាតិនាទីក្រុងនូរ៉ាំប៊ឺហ្គ ឬទៅលើទំនាក់ទំនងជាមួយនឹងជម្លោះប្រដាប់អាវុធឡើយ[39]។

២៣- ភស្តុតាងដទៃទៀតអំពីទម្លាប់អនុវត្តរបស់រដ្ឋ និង*ភាតព្វកិច្ចតាមផ្លូវច្បាប់* នៅមុនឆ្នាំ១៩៧៥ គឺជាការគាំទ្របន្ថែមទៀតដល់សញ្ញាណ ដែលថាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិដែលអាចត្រូវបានប្រព្រឹត្តនៅក្រៅ

[35] *សូមអាន* សាលដីការបស់អង្គបុរេជំនុំជម្រះលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាសម្រេចរបស់សហចៅក្រមស៊ើបអង្កេតស្តីពីសហកម្មឧក្រិដ្ឋកម្មរួម (JCE), សំណុំរឿងលេខ ០០២/១៩-០៩-២០០៧-អវតក/ កសចស (អបជ៣៨), ឯកសារលេខ D97/15/9, ចុះថ្ងៃទី២០ ឧសភា ២០១០, កថាខណ្ឌទី ៥៧ (សង្កត់ន័យបន្ថែមដោយអក្សរទ្រេត)។

[36] *សូមអាន ឧទាហរណ៍ដូចជា* សាលដីកាលើបណ្តឹងឧទ្ធរណ៍ស្តីពីយុត្តាធិការរបស់ Tadić, កថាខណ្ឌទី ១៤០។ *រដ្ឋអាជ្ញា ទល់នឹង Kupreskic*, សាលក្រម, សំណុំរឿងលេខ IT-95-16-A, អង្គជំនុំជម្រះសាលាដំបូង ICTY, ថ្ងៃទី១៤ មករា ២០០០, កថាខណ្ឌទី ៥៤១ (ដោយបានបញ្ជាក់ថា CCL 10 គឺជាលិខិតុបករណ៍មួយក្នុងចំណោមលិខិតុបករណ៍អន្តរជាតិ “ដែលចែងពីបទប្បញ្ញត្តិនានា ដែលប្រកាសពីអត្ថិភាពច្បាប់ ឬមួយក៏ត្រូវបានប្រែក្លាយជាបន្តបន្ទាប់ទៅជា ច្បាប់តាមទម្លាប់អន្តរជាតិ”) ។

[37] *ករណីរឿងក្តីរបស់ រដ្ឋអាជ្ញា ទល់នឹង Tadić* , សេចក្តីសម្រេចលើញត្តិស្នើសុំរបស់មេធាវីការពារក្តីស្តីពីយុត្តាធិការ, សំណុំរឿងលេខ IT-94-I-T, អង្គជំនុំជម្រះសាលាដំបូងទី II នៃតុលាការ ICTY, ចុះថ្ងៃទី១០ សីហា ១៩៩៥, កថាខណ្ឌទី ១៤០ ។ *សូមអានផងដែរ* សាលក្រមលើសំណុំរឿងលេខ០០១, កថាខណ្ឌទី ២៩២ (ដែលលើកសំអាងលើអនុសញ្ញាអន្តរជាតិនានាស្តីពីឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ និងរបបអាប៉ាថេត ធ្វើជាភស្តុតាងដែលពាក់ព័ន្ធអំពីថា តើទំនាក់ទំនងគ្នារវាងជម្លោះប្រដាប់អាវុធមួយតើនៅក្រោមច្បាប់ទម្លាប់អន្តរជាតិលក្ខខណ្ឌតម្រូវឲ្យមានដែរឬទេ នៅក្នុងអម្លុងពេលពីឆ្នាំ១៩៧៥-១៩៧៩)។

[38] អនុសញ្ញាស្តីពីការទប់ស្កាត់ និងផ្តន្ទាទោសចំពោះឧក្រិដ្ឋកម្មប្រល័យពូជសាសន៍, ចុះថ្ងៃទី៩ ធ្នូ ១៩៤៨, 78 UNTS 277, មាត្រា១ ។

[39] អនុសញ្ញាអន្តរជាតិស្តីពីការលប់បំបាត់ និងផ្តន្ទាទោសចំពោះឧក្រិដ្ឋកម្មអាប៉ាថេត, ចុះថ្ងៃទី៣០ វិច្ឆិកា១៩៧៣, ឯកសារលេខ 1015 UNTS 243, មាត្រាI។

ជម្លោះប្រដាប់អាវុធ។ សេចក្តីព្រាងក្រមស្តីពីបទល្មើសនានាប្រឆាំងនឹងសន្តិភាព និងសន្តិសុខរបស់មនុស្សជាតិឆ្នាំ១៩៥៤របស់គណៈកម្មាធិការច្បាប់អន្តរជាតិ បានកំណត់និយមន័យនៃឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ និង "អំពើអមនុស្សធម៌នានា.....ប្រឆាំងប្រជាជនស៊ីវិលណាមួយ" ដោយគ្មានភ្ជាប់បទល្មើសនានា ទៅនឹងជម្លោះប្រដាប់អាវុធ[40]។ ស្រដៀងគ្នានេះ អនុសញ្ញាឆ្នាំ១៩៦៨ ស្តីពីភាពមិនអាចអនុវត្តបាននៃអាជ្ញាយុកាលចំពោះឧក្រិដ្ឋកម្មសង្គ្រាម និងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ដែលត្រូវបានអនុវត្តចំពោះឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ដែល"បានប្រព្រឹត្តទោះបីជានៅក្នុងពេលសង្គ្រាម ឬក្នុងពេលសន្តិភាពក៏ដោយ"[41]។ លើសពីនេះ ច្បាប់ក្នុងស្រុក ដូចជា ច្បាប់ឆ្នាំ១៩៥០ ស្តីពី(ការផ្តន្ទាទោស) របប Nazi អ៊ីស្រាអែល និងសហការីទាំងឡាយនៃរបប Nazi ត្រូវបានគេប្រើប្រាស់សំរាប់កាត់ទោសចំពោះ Adolf Eichmann និង John Demjanjuk, ដែលមិនមានលក្ខខណ្ឌតម្រូវឱ្យមានទំនាក់ទំនងទៅវិញទៅមកណាមួយនោះឡើយ[42]។

## ខ. ជនចាប់ចោទអាចរកបាន និងអាចព្យាករទុកជាមុនបានថា គេអាចដាក់ឱ្យពួកគាត់ទទួលខុសត្រូវចំពោះឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិដែលបានប្រព្រឹត្តនៅខាងក្រៅជម្លោះប្រដាប់អាវុធ

២៤- ពាក់ព័ន្ធនឹងការកំណត់បទចោទពីឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ នៅក្នុងឆ្នាំទាំងឡាយ រហូតដល់ឆ្នាំ ១៩៧៥ គឺគេអាចព្យាករទុកជាមុនបាន ដោយមិនមានការសង្ស័យអ្វីទេថា គេអាចដាក់ឱ្យជនជាប់ចោទ

[40] សេចក្តីព្រាងក្រមស្តីពីបទល្មើសប្រឆាំងនឹងសន្តិភាពនិងសន្តិសុខរបស់មនុស្សជាតិរបស់គណៈកម្មការច្បាប់អន្តរជាតិ, ឯកសារលេខUN Doc A/2693 (ឆ្នាំ១៩៥៤) មាត្រា២(១០-១១)[ដែលជាបន្តមកទៀតនៅក្នុងនេះហៅកាត់"សេចក្តីព្រាងក្រមពីបទល្មើស ILC"]។

[41] ឯកសារ UN Doc លេខ A/RED/2391 (XXIII), ចុះថ្ងៃទី២៦ វិច្ឆិកា ១៩៦៨, ឧបសម្ពន្ធ,មាត្រា១.ខ។ ទោះបីជាអនុសញ្ញាបានលើកយោងទៅលើនិយមន័យនៃឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិនៅក្នុង IMT Charter ក៏ដោយក៏ វាក្យខណ្ឌដែលនៅខាងបន្ទាប់គ្នាពីខាងមុខនេះដែលថែងថា "ទោះជាប្រព្រឹត្តនៅក្នុងពេលសង្គ្រាម ឬមួយក្នុងពេលសន្តិភាពក៏ដោយ", ដែលជាការបញ្ជាក់ច្បាស់ថា ទំនាក់ទំនងគ្នាទៅវិញទៅមកនៃជម្លោះប្រដាប់អាវុធមិនត្រូវបានគេយកមកអនុវត្តទេ។ *សូមអាន ដូចគ្នានឹងខាងលើ* (មិនមានអាជ្ញាយុកាលណាត្រូវបានយកមកអនុវត្តចំពោះ "ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិនោះទេ *ទោះជាប្រព្រឹត្តនៅក្នុងពេលសង្គ្រាមឬមួយក្នុងពេលសន្តិភាពក៏ដោយ*' ដូចដែលត្រូវបានកំណត់និយមន័យនៅក្នុងធម្មនុញ្ញរបស់តុលាការសឹកអន្តរជាតិ...") ។ (ការសង្កត់ន័យបន្ថែមដោយ *អក្សរទ្រេត*)

[42] វាក្យខណ្ឌ ១.ខ នៃលក្ខន្តិកៈអ៊ីស្រាអែលថែងថា៖ "ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ" មានន័យថាជាអំពើណាមួយក្នុងចំណោមអំពើទាំងឡាយដូចតទៅនេះ៖ ការធ្វើមនុស្សឃាត ការសម្លាប់រង្គាល ការធ្វើឱ្យទៅជាទាសករ ការបង្អត់អាហារ ឬ ការនិរទេស និងអំពើអមនុស្សធម៌ផ្សេងៗទៀត ដែលត្រូវបានប្រព្រឹត្តទៅលើប្រជាជនស៊ីវិលណាមួយក៏ដោយ, ហើយនិងការធ្វើទុក្ខបុកម្នេញដោយមូលហេតុ ជាតិ ពូជសាសន៍ សាសនា ឬ នយោបាយ", ច្បាប់ស្តីពី(ការផ្តន្ទាទោសលើ)របប Nazi និងពួកអ្នកចូលដៃនឹងរបប Nazi, ៥៧១០ (ឆ្នាំ១៩៥០) ។ *សូមមើលផងដែរ,* ច្បាប់របស់ប្រទេសបង់ក្លាដែស លេខ XIX ឆ្នាំ១៩៧៣, ច្បាប់ស្តីពី(តុលាការ)ព្រហ្មទណ្ឌអន្តរជាតិ, ថ្ងៃទី២០ កក្កដា ១៩៧៣, មាត្រា៣.២.ក (ដោយបានហាមឃាត់ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ, ដែលបានឱ្យនិយមន័យមិនខុសគ្នាពីធម្មនុញ្ញ IMT Charter ឬ លក្ខខណ្ឌតម្រូវស្តីពីទំនាក់ទំនងនៃជម្លោះប្រដាប់អាវុធណាមួយក៏ដោយ នោះឡើយ) ។

ទទួលខុសត្រូវចំពោះឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិដែលបានប្រព្រឹត្តនៅក្នុងប្រទេសកម្ពុជា មិនថាមាន ឬគ្មានអត្ថិភាពនៃជម្លោះប្រដាប់អាវុធមួយនៅពេលពាក់ព័ន្ធគ្នានោះឡើយ។ ដូចដែលអង្គបុរេជំនុំជម្រះបានទទួលស្គាល់ហើយថា បទដ្ឋានសម្រាប់ការព្យាករណ៍ទុកជាមុនតម្រូវថា "ជនត្រូវចោទត្រូវតែមានលទ្ធភាព វាយតម្លៃខ្ពស់បានអំពើនោះ គឺមានលក្ខណៈឧក្រិដ្ឋនៅក្នុង ន័យដែលយល់បានជាទូទៅដោយពុំមានការយោងទៅដល់បញ្ញត្តិជាក់លាក់ណាមួយឡើយ"[43]។ ជាការពិតណាស់ អំពើដ៏សាហាវយង់ឃ្នងនានាដែលបានប្រព្រឹត្តក្នុងប្រទេសកម្ពុជា ក្នុងអំឡុងឆ្នាំ១៩៧៥-១៩៧៩ គឺមានលក្ខណៈ "ឧក្រិដ្ឋនៅក្នុងន័យដែលយល់បានជាទូទៅ" ដោយពុំចាំបាច់ថា វាមាន ឬគ្មានជាប់ទាក់ទង ទៅនឹងជម្លោះប្រដាប់អាវុធនោះឡើយ។ ព័ត៌មានចាំបាច់ក្នុងការឈានទៅដល់សេចក្តីសន្និដ្ឋាននេះ គឺមានលក្ខណៈជាសាធារណៈ និងដែលអាចរកបានរួចជាស្រេច[44]។

២៥- សូម្បីតែវាមានកម្រិតមួយនៃភាពមិនជាក់លាក់ច្បាស់លាស់ ដែលពាក់ព័ន្ធនឹងការកំណត់បទចោទពីឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិចាប់ពីឆ្នាំ១៩៧៥ក៏ដោយ ក៏គេធ្លាប់បានទទួលស្គាល់ថា គោលការណ៍ស្តីពីនីត្យានុកូលភាព "មិនបានរារាំងតុលាការមួយមិនឱ្យធ្វើការបកស្រាយ និងធ្វើការបញ្ជាក់ពីធាតុផ្សំនានានៃឧក្រិដ្ឋកម្មជាក់លាក់នោះទេ" ហើយវាក៏មិនបានច្រានចោលជាមុននូវការចម្រើន ជឿនលឿនជាលំដាប់នៃច្បាប់ដោយសារតុលាការនោះដែរ"[45]។ តាមពិតទៅ អំពីវិសាលភាពដែលថា វាពុំមានភាពច្បាស់លាស់អំពីថាតើលក្ខខណ្ឌតម្រូវស្តីពីអត្ថិភាពនៃទំនាក់ទំនង ក្នុងចន្លោះឆ្នាំ១៩៧៥-១៩៧៩ ដំណោះស្រាយតាមសេចក្តីសម្រេចចុងក្រោយតាមផ្លូវតុលាការ អំពីភាពមិនច្បាស់លាស់នោះ គឺអាចព្យាករទុកជាមុនបានរួចស្រេច[46]។ ទាក់ទងនឹងសន្និសញ្ញាអន្តរជាតិ និងភ័ស្តុតាងស្តីពីការអនុវត្តរបស់រដ្ឋដែល

[43] សាលដីកាអបជ លើបណ្តឹងឧទ្ធរណ៍របស់ នួន ជា និង អៀង ធីរិទ្ធ ប្រឆាំងនឹងដីកាដំណោះស្រាយ, ថ្ងៃទី១៥ កុម្ភៈ ២០១១, កថាខណ្ឌ១០៦។

[44] ក្នុងឋានៈជាសមាជិកម្នាក់នៃមហាសន្និបាតអង្គការសហប្រជាជាតិ របបកម្ពុជាប្រជាធិបតេយ្យ និងមន្ត្រីផ្លូវការជាន់ខ្ពស់របស់ខ្លួន ត្រូវតែបានដឹងអំពីលិខិតុបករណ៍អន្តរជាតិដែលពាក់ព័ន្ធទៅនឹងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ដោយពុំមានការសង្ស័យអ្វីឡើយ ។ *សូមមើល, ឧទាហរណ៍.* របាយការណ៍របស់លោកអគ្គលេខាធិការ, UN S/13021, ថ្ងៃទី១១ មករា ១៩៧៩, (មានភ្ជាប់លិខិតមួយពី អៀង សារី បញ្ជាក់ពីសមាសភាពគណៈប្រតិភូនៃកម្ពុជាប្រជាធិបតេយ្យ ទៅកាន់មហាសន្និបាតអង្គការសហប្រជាជាតិ) ។

[45] *រដ្ឋអាជ្ញា ទល់នឹង Milutinovic និងគូកន*, សាលដីកាលើញត្តិរបស់ Ojdanic ជំទាស់នឹងយុត្តាធិការ - សហកម្មឧក្រិដ្ឋកម្មរួម - សំណុំរឿងលេខ IT-99-37-AR72, អង្គជំនុំជម្រះសាលាឧទ្ធរណ៍ ICTY, ថ្ងៃទី២១ ឧសភា ២០០៣ [បន្ទាប់ពីនេះទៅហៅថា សាលដីកាស្តីពី JCE លើករណីរបស់ *Milutinovic*], កថាខណ្ឌទី ៣៨ ។

[46] *សូមមើល, SW ទល់នឹង* ចក្រពភអង់គ្លេស, ECHR, ថ្ងៃទី២២ វិច្ឆិកា ១៩៩៥, Ser A 335-B, កថាខណ្ឌទី ៣២-៤៣ (ដោយរកឃើញថា ការដកហូតអភ័យឯកសិទ្ធិរបស់ប្តីចេញពីការចោទប្រកាន់ក្នុងករណីរំលោភសេពសន្ថវៈលើប្រពន្ធរបស់គាត់គឺមានលក្ខណៈ "អាចព្យាករទុកជាមុនបានយ៉ាងសមហេតុសមផល តាមប្រឹក្សាផ្លូវច្បាប់ដ៏សមស្រប" ។

បានពិចារណាទៅខាងដើម សេចក្តីសម្រេចចុងក្រោយនេះស្ថិតនៅយ៉ាងសមស្របក្នុង "កម្រិតដ៏សមហេតុសមផលនៃភាពច្បាស់លាស់មួយដែលអាចទទួលយកបាន"[47]។

២៦- សេចក្តីសន្និដ្ឋាននេះ ត្រូវបានគាំទ្រដោយចរិតដែលគួរឱ្យស្អប់ខ្ពើមជាខ្លាំងនៃអំពើឧក្រិដ្ឋ ដែលត្រូវបានប្រព្រឹត្តក្នុងប្រទេសកម្ពុជា ពីឆ្នាំ១៩៧៥ ដល់ឆ្នាំ១៩៧៩ ដែលថាខណៈដែលវាមិនមែនជា យុត្តិកម្មតែឯកឯងសម្រាប់ធ្វើពិរុទ្ធកម្មនោះទេ គឺធ្វើឱ្យវាទៅជាមិនអាចយល់បាន ដែលថាបុគ្គលដ៏ សមហេតុសមផលមួយរូប អាចនឹងជឿជាក់បានថា អំពើដ៏សាហាវយង់ឃ្នងបែបដូច្នេះ មិនបានរំលោភទៅលើសេចក្តីថ្លែងជាសាកលអំពីច្បាប់ និងពីភាពសមរម្យ នោះឡើយ[48]។

## គ. គោលការណ៍ស្តីពី ***វិមតិសង្ស័យត្រូវបានជាប្រយោជន៍ដល់ជនជាប់ចោទ***មិនបានធ្វើជាមូលដ្ឋានមួយដ៏ត្រឹមត្រូវសម្រាប់ដោះស្រាយជម្លោះពាក់ព័ន្ធនឹងស្ថានភាពនៃច្បាប់ទម្លាប់អន្តរជាតិទេ

២៧- អង្គបុរេជំនុំជម្រះបានធ្វើយុត្តិកម្មលើសេចក្តីសន្និដ្ឋានរបស់ខ្លួនលើលក្ខខណ្ឌតម្រូវ ស្តីពីទំនាក់ទំនងនៃជម្លោះប្រដាប់អាវុធមួយនៅក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះ ដោយមានមូលដ្ឋានមួយ ដែលថា ឋានៈនៃច្បាប់ទំនៀមទម្លាប់អន្តរជាតិ ដែលទាក់ទងទៅនឹងលក្ខខណ្ឌតម្រូវស្តីពីទំនាក់ទំនងនៃជម្លោះប្រដាប់អាវុធនោះគឺវាមិនច្បាស់លាស់ទេ[49]។ ព្រោះហេតុដូច្នេះហើយបានជាគោលការណ៍ស្តីពី *វិមតិសង្ស័យត្រូវបានជាប្រយោជន៍ជនជាប់ចោទ* បានតម្រូវឱ្យអង្គបុរេជំនុំជម្រះវិនិច្ឆ័យសេចក្តី ដោយផ្តល់ប្រយោជន៍ឱ្យដល់ជនសង្ស័យ[50]។ ទោះបីជាអង្គជំនុំជម្រះសាលាដំបូងមិនជាប់កាតព្វកិច្ច ដោយសេចក្តីសម្រេចរបស់អង្គបុរេជំនុំជម្រះក៏ដោយ ក៏នៅទីនេះសហព្រះរាជអាជ្ញាកត់ត្រានូវការជំទាស់របស់ខ្លួន ប្រឆាំងនឹងការ

---

[47] សាលដីកាស្តីពី JCE លើករណីរបស់ *Milutinovic*], កថាខណ្ឌទី ៣៨ ។

[48] សាលដីកាស្តីពី JCE លើករណីរបស់ *Milutinovic*, សំណុំរឿងលេខ IT-99-37-AR72, អង្គជំនុំជម្រះសាលាឧទ្ធរណ៍ ICTY, ថ្ងៃទី២១ ឧសភា ២០០៣, កថាខណ្ឌទី ៤២ (ដោយថ្លែងថា "ទោះបី ជាភាពខ្វះសីលធម៌ ឬចរិតដ៏រន្ធត់នៃអំពើមួយ មិនមែនជាកត្តាគ្រប់គ្រាន់ដើម្បីធានាពី ការធ្វើពិរុទ្ធកម្មនៅក្រោមច្បាប់តាមទម្លាប់អន្តរជាតិក៏ដោយ ក៏តាមពិត វាអាចដើរតួនាទីមួយនៅក្នុងប្រការនោះ ក្នុងទំហំមួយដែលថាវាអាចនឹង បដិសេធលើការអះអាងណាមួយដោយមេធាវីការពារក្តី ដែលថាវាមិនបានដឹងពីចរិតលក្ខណៈឧក្រិដ្ឋនៃអំពើនោះ") ។

[49] សាលដីការបស់ អបជ លើបណ្តឹងឧទ្ធរណ៍របស់ នួន ជា និង អៀង ធីរិទ្ធ ប្រឆាំងនឹងដីកាដំណោះស្រាយ, D427/3/15, ថ្ងៃទី១៥ កុម្ភៈ ២០១១, កថាខណ្ឌទី ១៣៧ ។ *សូមមើលផងដែរ* សាលដីការបស់ អបជ លើបណ្តឹងឧទ្ធរណ៍របស់ អៀង សារី ប្រឆាំងនឹងដីកាដំណោះស្រាយ, ថ្ងៃទី១១ មេសា ២០១១, កថាខណ្ឌទី ៣០៩ ។

[50] សាលដីការបស់ អបជ លើបណ្តឹងឧទ្ធរណ៍របស់ នួន ជា និង អៀង ធីរិទ្ធ ប្រឆាំងនឹងដីកាដំណោះស្រាយ, D427/3/15, ថ្ងៃទី១៥ កុម្ភៈ ២០១១, កថាខណ្ឌទី ១៤៤ ។ សាលដីការបស់ អបជ លើបណ្តឹងឧទ្ធរណ៍របស់ អៀង សារី ប្រឆាំងនឹងដីកាដំណោះស្រាយ, ថ្ងៃទី១១ មេសា ២០១១, កថាខណ្ឌទី ៣១០ ។

បកស្រាយរបស់អង្គបុរេជំនុំជម្រះ និងការអនុវត្តនូវគោលការណ៍ស្តីពី *វិមតិសង្ស័យត្រូវបានជាប្រយោជន៍ជនជាប់ចោទ*។ ដោយឡែក សហព្រះរាជអាជ្ញាសន្និដ្ឋានថាគោលការណ៍ស្តីពី *វិមតិសង្ស័យត្រូវបានជាប្រយោជន៍ដល់ជនជាប់ចោទ* - ដែលបានយល់ដឹងយ៉ាងត្រឹមត្រូវ - គឺជាវិធាន ស្តីពីសក្ខីកម្ម មិនមែនជាវិធានស្តីពីការបកស្រាយច្បាប់នោះទេ។ ហេតុដូច្នេះ គោលការណ៍នេះមិនអាចប្រើប្រាស់ធ្វើជាមូលដ្ឋានមួយក្នុងការដោះស្រាយជម្លោះនានា ស្តីពីបញ្ហាច្បាប់សុទ្ធសាធនោះឡើយ ជាពិសេសជម្លោះនានាស្តីពីការបកស្រាយច្បាប់តាមទំនៀមទម្លាប់អន្តរជាតិឲ្យបានត្រឹមត្រូវ។

២៨- ដោយអនុលោមតាមទម្ងន់នៃច្បាប់ជាតិ និងច្បាប់អន្តរជាតិ គោលការណ៍ស្តីពី *វិមតិសង្ស័យត្រូវបានជាប្រយោជន៍ដល់ជនជាប់ចោទ* បានផ្តល់នូវផលប្រយោជន៍នៃការសង្ស័យដល់ជនជាប់ចោទ កាលណាមានភាពមិនច្បាស់លាស់អំពីថាតើភស្តុតាងនោះមានលក្ខណៈគ្រប់គ្រាន់ដែរឬទេ ដើម្បីគាំទ្រដល់ការកាត់សេចក្តីមួយ។ ដូចដែលអង្គជំនុំជម្រះសាលាដំបូង និងសាលាឧទ្ធរណ៍នៃតុលាការ ICTY ធ្លាប់បានសម្រេចដូច្នោះដែរ ថាគោលការណ៍ស្តីពី *វិមតិសង្ស័យត្រូវបានជាប្រយោជន៍ដល់ជនជាប់ចោទ* "អាចអនុវត្តបានចំពោះការរកឃើញនូវអង្គហេតុនានា ហើយមិនមែនការរកឃើញនូវ អង្គច្បាប់នោះឡើយ"[51] ព្រមទាំង"ព័ទ្ធវង់ទៅលើការសង្ស័យនានាអំពី ថាតើបទល្មើសមួយត្រូវបានបង្ហាញសក្ខីកម្មនៅពេលធ្វើសេចក្តីសន្និដ្ឋានលើសំណុំរឿងដែរ ឬទេ"[52]។ ការវិភាគលើគោលការណ៍ស្តីពី *វិមតិសង្ស័យត្រូវបានជាប្រយោជន៍ដល់ជនជាប់ចោទ* ដែលមានអះអាងនៅក្នុងយុត្តិសាស្ត្រអន្តរជាតិ បានឆ្លុះបញ្ចាំងពីការយល់ឃើញលើគោលការណ៍នេះ។ ជាឧទាហរណ៍ នៅក្នុងករណី *រដ្ឋអាជ្ញា ទល់នឹង* *Renzahu* អង្គជំនុំជម្រះសាលាឧទ្ធរណ៍តុលាការICTR បានច្រានចោលនូវការទាមទាររបស់មេធាវីការពារក្តីដែលថា អង្គជំនុំជម្រះសាលាដំបូងមានការខកខានពុំបានពិចារណាឲ្យបានត្រឹមត្រូវ ពីការសង្ស័យពាក់ព័ន្ធនឹងចារី និងពីកាលៈទេសៈនៃការស្លាប់របស់បុគ្គលជាក់លាក់នានា ហើយបានយោងទៅដល់គោលការណ៍ស្តីពី *វិមតិសង្ស័យត្រូវបានជាប្រយោជន៍ដល់ជនជាប់ចោទ* "ថាជាអនុសាឲ្យមួយ ចំពោះសច្ចធារណ៍នៃនីរទោស និងចំពោះបន្ទុកភស្តុតាងឲ្យបានហួសពីវិមតិសង្ស័យ"[53]។ ការយល់ឃើញដូចគ្នានេះ អំពីគោលការណ៍

---

[51] *រដ្ឋអាជ្ញា ទល់នឹង Stakic*, សាលក្រម, សំណុំរឿងលេខ IT-97-24-T, អង្គជំនុំជម្រះសាលាដំបូង ICTY, ថ្ងៃទី៣១ កក្កដា ២០០៣, កថាខណ្ឌទី ៤១៦, ៥១០ ។

[52] *រដ្ឋអាជ្ញា ទល់នឹង Galic*, សាលដីកា, សំណុំរឿងលេខ IT-98-29-A, អង្គជំនុំជម្រះសាលាឧទ្ធរណ៍ ICTY, ថ្ងៃទី៣០ វិច្ឆិកា ២០០៦, កថាខណ្ឌទី ៧៧។

[53] *រដ្ឋអាជ្ញា ទល់នឹង Renzahu*, សំណុំរឿងលេខ ICTR-97-31-A, សាលដីកា, ថ្ងៃទី១ មេសា ២០១១, កថាខណ្ឌទី ៤៧២-៤៧៥ ។ *សូមមើលផងដែរ, រដ្ឋអាជ្ញា ទល់នឹង Halilovic*, សាលដីកា, សំណុំរឿងលេខ IT-01-48-A, ថ្ងៃទី១៦ តុលា ២០០៧, កថាខណ្ឌទី ១០៩

ស្តីពី *វិមតិសង្ស័យត្រូវបានជាប្រយោជន៍ដល់ជនជាប់ចោទ* ត្រូវបានឆ្លុះបញ្ចាំងនៅក្នុងយុត្តាធិការតាមប្រទេសនានា រួមទាំងប្រទេសបារាំងផង ដែលច្បាប់របស់ខ្លួនមានឥទ្ធិពលយ៉ាងខ្លាំងទៅលើច្បាប់របស់ប្រទេសកម្ពុជា[54]។

២៩- ខណៈដែលវានៅតែជាការពិតដែលថាមានចៅក្រម និងអ្នកធ្វើអត្ថាធិប្បាយតិចតួចប៉ុណ្ណោះ ដែលធ្លាប់បានលើកទឹកចិត្តឲ្យមានការយល់ដឹងយ៉ាងទូលំទូលាយអំពី *វិមតិសង្ស័យត្រូវបានជាប្រយោជន៍ដល់ជនជាប់ចោទ* ខណៈដែលមានភាពមិនច្បាស់លាស់នៅក្នុងការបកស្រាយច្បាប់ ត្រូវបានគេបកស្រាយដោយផ្តល់ប្រយោជន៍ដល់ជនជនជាប់ចោទ[55]។ សហព្រះរាជអាជ្ញាមិនដឹងថាមានយុត្តិសាស្ត្រអន្តរជាតិណាមួយ ខណៈដែលការបកស្រាយយ៉ាងទូលំទូលាយនូវគោលការណ៍ស្តីពី *វិមតិសង្ស័យត្រូវបានជាប្រយោជន៍ដល់ជនជាប់ចោទ*, ដោយខ្លួនផ្ទាល់, ធ្លាប់ត្រូវបានតុលាការមួយនោះយកទៅអនុវត្ត ក្នុងគោលបំណងដើម្បីកំណត់រកនូវបញ្ហាច្បាប់[56]។ តាមអង្គហេតុពិត ការបកស្រាយបែបដូច្នេះ មានអត្ថិភាពជាមួយគ្នាមិនងាយស្រួលឡើយទៅនឹងសុភាសិតជាមូលដ្ឋានមួយថា *iura novit curia* ("the judge knows the law") "ចៅក្រមចេះច្បាប់"។ ការព្រមតាមដោយស្វ័យប្រវត្តិទៅនឹងជនជាប់ចោទកាលណាការចោទប្រកាន់ខកខានមិនបានដាក់ជូននូវភស្តុតាងឲ្យបានគ្រប់គ្រាន់ ដើម្បីគាំទ្របន្ទុកក្នុងការផ្តល់

---

(ដោយឆ្លុះបញ្ចាំងការយល់ដឹងពី *វិមតិសង្ស័យត្រូវបានជាប្រយោជន៍ដល់ជនជាប់ចោទ* ថាជាគោលការណ៍មួយទាក់ទងទៅនឹងការបកស្រាយនូវភស្តុតាង ប្រឆាំងនឹងជនជាប់ចោទ) ។

[54] *រដ្ឋអាជ្ញា ទល់នឹង Limaj*, សេចក្តីប្រកាសរបស់ចៅក្រម Schomburg, សំណុំរឿងលេខ IT-03-66-A, ថ្ងៃទី២៧ កញ្ញា ២០០៧, កថាខណ្ឌទី ១៧ (ដោយស្រង់អភិប្រាយមួយរបស់បារាំង (a French treatise) ដែលបញ្ជាក់ថា គោលការណ៍ស្តីពី *វិមតិសង្ស័យត្រូវបានជាប្រយោជន៍ដល់ជនជាប់ចោទ* មិនអាចអនុវត្តបានចំពោះការបកស្រាយលើអង្គច្បាប់បានទេ ប៉ុន្តែផ្ទុយទៅវិញ វាគឺជាវិធានមួយដែលតម្រូវឲ្យមានការលើកលែងការចោទប្រកាន់លើជនជាប់ចោទណាម្នាក់កាលណាភស្តុតាងដែលបានដាក់ជូននោះមិនគ្រប់គ្រាន់សម្រាប់ធ្វើជាមូលដ្ឋានក្នុងការចោទប្រកាន់) ។

[55] *សូមមើល, រដ្ឋអាជ្ញា ទល់នឹង Limaj*, សេចក្តីប្រកាសរបស់ចៅក្រម Shahabuddeen, សំណុំរឿងលេខ IT-03-66-A, ថ្ងៃទី២៧ កញ្ញា ២០០៧, កថាខណ្ឌទី២ (ដោយថ្លែងពីទស្សនៈរបស់គាត់ថា *វិមតិសង្ស័យត្រូវបានជាប្រយោជន៍ដល់ជនជាប់ចោទ* អាចអនុវត្តបានទាំងបញ្ហាអង្គហេតុ និងទាំងបញ្ហាអង្គច្បាប់) ។

[56] គោលការណ៍ស្តីពី *វិមតិសង្ស័យត្រូវបានជាប្រយោជន៍ដល់ជនជាប់ចោទ* (principle of *in dubio pro reo*) គឺខុសគ្នាពី "វិធានស្តីពីភាពអត់អោន (rule of lenity)" ឬ គោលការណ៍ស្តីពី *ការជំទាស់នឹងបុគ្គលដែលស្នើលក្ខខណ្ឌ* (principle of *contra proferentum*) ដែលជួនកាល ត្រូវបានអនុវត្តនៅក្នុងការបកស្រាយភាសាក្នុងលក្ខន្តិកៈដែលមានន័យមិនច្បាស់លាស់ កាលណាវិធានស្តីពីការសន្និដ្ឋាន (rules of construction) ផ្សេងៗទៀតមិនអាចដោះស្រាយបញ្ហានោះបាន ។ *សូមមើល, ឧទាហរណ៍,* អង្គជំនុំជម្រះពិសេសសម្រាប់ប្រទេសលីបង់, វិធានស្តីពីភស្តុតាង និងនីតិវិធី (វិសោធនកម្ម ថ្ងៃទី២៩ វិច្ឆិកា ២០១០), វិធាន ៣ (ដែលចែងពីដំណោះស្រាយស្តីពីការសង្ស័យ នៅក្នុងការបកស្រាយវិធានជាប្រយោជន៍ជនជាប់ចោទ បើសិនតែមួយនេះគត់ គឺកាលណាវិធានស្តីពីការសន្និដ្ឋានជាក់លាក់ដទៃទៀតមិនមានលក្ខណៈគ្រប់គ្រាន់ក្នុងការបញ្ជាក់អត្ថបទឲ្យបានច្បាស់។ វិធានស្តីពីការសន្និដ្ឋានត្រូវតែបានអនុវត្តជាដំបូង រួមមាន៖ ទី១) គោលការណ៍ស្តីពីការបកស្រាយដែលបានចងជាក្រមក្នុងមាត្រា ៣១-៣៣ នៃអនុសញ្ញាទីក្រុងវីយែន ស្តីពីច្បាប់សន្ធិសញ្ញា, ទី២) បទដ្ឋានស្តីពីសិទ្ធិមនុស្សអន្តរជាតិ, ទី៣) គោលការណ៍ទូទៅស្តីពីច្បាប់ និងនីតិវិធីព្រហ្មទណ្ឌអន្តរជាតិ, និងទី៤) ក្រមនីតិវិធីព្រហ្មទណ្ឌរបស់ប្រទេសលីបង់) ។

ភ័ស្តុតាងគឺជារឿងមួយ, រីឯការព្រមតាមដោយស្វ័យប្រវត្តិទៅនឹងជនជាប់ចោទនៅពេលណាដែលច្បាប់មានការពិបាកក្នុងការធ្វើឱ្យដឹងជាប្រាកដ វាជារឿងផ្សេងមួយទៀតទាំងស្រុង។ ដូចដែល ចៅក្រម Schomburg បានថ្លែងនៅក្នុងសេចក្តីប្រកាសមួយរបស់ខ្លួននៅក្នុងករណី *រដ្ឋអាជ្ញា ទល់នឹង Limaj* ថា៖

> “វាជាករណីយកិច្ច និងកាតព្វកិច្ចដ៏ថ្លៃថ្នូររបស់តុលាការខ្លួនឯង ក្នុងការធ្វើឱ្យដឹងប្រាកដ និងអនុវត្តច្បាប់ពាក់ព័ន្ធនៅក្នុងកាលៈទេសៈនៃករណីរឿងណាមួយ, ពីព្រោះច្បាប់ស្ថិតនៅលើចំណេះដឹងផ្នែកយុត្តិធម៌របស់តុលាការដែលសម្រេចតាមគោលការណ៍ច្បាប់។ នៅក្នុងការកំណត់សម្រេចនេះ វាមិនមានអ្វីដែលគួរឱ្យសង្ស័យទៀតឡើយ...។ តុលាការត្រូវតែឈានទៅដល់សេចក្តីសន្និដ្ឋានដាច់ខាតមួយតែប៉ុណ្ណោះ។ តុលាការអាចនឹងមានការខុសឆ្គង នៅក្នុងការកំណត់សម្រេចនេះដែលអាចត្រូវបានធ្វើការកែតម្រូវនៅពេលខទ្ធរណ៍។ ទោះជាយ៉ាងដូច្នេះក៏ដោយ ក៏តុលាការដែលសម្រេចតាមគោលការណ៍ច្បាប់មិនអាចបន្សល់ទុកនូវការសង្ស័យណាមួយ ដែលស្តីពីការបកស្រាយដ៏ត្រឹមត្រូវលើច្បាប់ពាក់ព័ន្ធនោះ បានទេ។ វាគឺជា*សេចក្តីថ្លៃថ្នូរនៃការិយាល័យ ឬអភ័យឯកសិទ្ធិ* និងជាកិច្ចការរបស់ចៅក្រម ដើម្បីធ្វើការវាយតម្លៃផ្តាច់ព្រ័តនោះ”[57]។

៣០- អង្គជំនុំជម្រះតុលាការកំពូលរបស់ អវតក បានពិភាក្សា*អំពីគោលការណ៍វិមតិសង្ស័យ ត្រូវបានជាប្រយោជន៍ដល់ជនជាប់ចោទ* នៅក្នុងបរិបទនៃជម្លោះអំពីអត្ថន័យដែលនៅក្នុងវិធានផ្ទៃក្នុងសម្រាប់ អវតក។ ជាដំបូងគេបង្អស់ អង្គជំនុំជម្រះនេះបានបញ្ជាក់ថា សិទ្ធិក្នុងការទទួលបាននូវការជំនុំជម្រះក្តីដោយត្រឹមត្រូវ ដែលរួមបញ្ចូលទាំងវិធាន២១នៃវិធានផ្ទៃក្នុង “មិនត្រូវបានបកស្រាយ ថាជាការអនុញ្ញាតដោយស្វ័យប្រវត្តិឱ្យជនជាប់ចោទទទួលបាននូវអត្ថប្រយោជន៍នៅគ្រប់រាល់ស្ថានភាពជាក់ស្តែងទាំងអស់ដែលកើតចេញមកពីការបកស្រាយវិធានផ្ទៃក្នុងនេះឡើយ”[58]។ អង្គជំនុំជម្រះនេះបន្តពន្យល់ថា “មុខងារជាចំបង” នៃគោលការណ៍*វិមតិសង្ស័យត្រូវបានជាប្រយោជន៍ដល់ជនជាប់*

---

[57] *សូមមើល, រដ្ឋអាជ្ញា ទល់នឹង Limaj*, សេចក្តីប្រកាសរបស់ចៅក្រម Schomburg, សំណុំរឿងលេខ IT-03-66-A, ថ្ងៃទី២៧ កញ្ញា ២០០៧, កថាខណ្ឌទី ១៦, ១៨ ។ *សូមមើលផងដែរ, ចក្រភពអង់គ្លេស ទល់នឹង ប្រទេសអ៊ីស្លង់,* តុលាការយុត្តិធម៌អន្តរជាតិ (ឆ្នាំ១៩៧៤) (ដោយថ្លែងថា ដោយសារវាជា “ករណីយកិច្ចរបស់តុលាការខ្លួនឯងក្នុងការធ្វើឱ្យដឹងប្រាកដ និងអនុវត្តច្បាប់ពាក់ព័ន្ធ នៅក្នុងកាលៈទេសៈនៃករណីរឿងណាមួយ, បន្ទុកក្នុងការបង្កើត និងផ្តល់សក្ខីកម្មលើវិធាននានានៃច្បាប់អន្តរជាតិ មិនអាចត្រូវបានដាក់បង្ខំទៅលើភាគីណាមួយ ក្នុងចំណោមភាគីនានាបានទេ ពីព្រោះច្បាប់ស្ថិតនៅលើចំណេះដឹងផ្នែកយុត្តិធម៌របស់តុលាការ”។

[58] សេចក្តីសំរេចរបស់អង្គជំនុំជម្រះតុលាការកំពូលលើបណ្តឹងសាទុក្ខភ្លាមៗរបស់ ខៀវ សំផន ស្តីពីសំណើសុំដោះលែង, សំណុំរឿងលេខ០០២/១៩-០៩-២០០៧-អវតក-អជសដ/តក (លេខ០៤),ឯកសារលេខ E50/3/1/4, ចុះថ្ងៃទី៦ មិថុនា ២០១១ [ដែលជាបន្ទាប់មកទៀតក្នុងនេះហៅថា “សេចក្តីសំរេចរបស់ អជតក លើពាក្យសុំដោះលែងរបស់ ខៀវ សំផន”], កថាខណ្ឌទី៣០។

*ចោទ* នៅក្នុងវិធានគឺ "ជាការចង្អុលបង្ហាញអំពីការគ្មានការរកឃើញ នៅក្នុងករណីដែលមានការសង្ស័យនានាលើអង្គហេតុដែលមិនត្រូវបានដកចេញដោយ ភ័ស្តុតាង" និងថា "ដោយហេតុថា គោលការណ៍ *វិមតិសង្ស័យត្រូវបានជាប្រយោជន៍ដល់ជនជាប់ចោទ* អាចអនុវត្តបានចំពោះទ្វេរគ្រោះនានាដោយសារអត្ថន័យនៅក្នុងច្បាប់ដែលត្រូវកំរិតត្រឹមតែថាជាការសង្ស័យ ដែលស្ថិតនៅជាដដែលក្រោយពី...ការអនុវត្តន៍នូវការបកស្រាយអំពីវិធាននានានៃប្រព័ន្ធច្បាប់ស៊ីវិលរួច នោះគឺបន្ទាប់ពីបានគិតគូរយកចិត្តទុកដាក់ទៅលើពាក្យពេចន៍ដែលនៅក្នុងសេចក្តីថែង ទៅលើទីកន្លែងរបស់វានៅក្នុងប្រព័ន្ធដែលរួមទាំងទំនាក់ទំនងរបស់វាទៅនឹងគោលការណ៍ ដែលសំខាន់ជាដើមអាទិ៍នានា និងគោលដៅរបស់វា"[59]។

៣១- ការអនុវត្តទ្រឹស្តីយ៉ាងទូលំទូលាយមួយស្តីពី *វិមតិសង្ស័យត្រូវបានជាប្រយោជន៍ជនជាប់ចោទ* គឺដោយឡែកមានពាក់ព័ន្ធនៅក្នុងបរិបទនៃច្បាប់តាមទម្លាប់អន្តរជាតិដែល - ដោយចរិតរបស់វាផ្ទាល់ - គឺមិនសូវមានលក្ខណៈត្រង់ៗ ដូចជាប្រភេទច្បាប់ផ្សេងៗទៀតឡើយ ហើយវាចាំបាច់ត្រូវតែឋិតនៅក្រោមដំណើរការនីតិវិធីមួយក្នុងការធ្វើសំយោគ និងសម្រេចតាមផ្លូវតុលាការដែលកំពុងតែប្រព្រឹត្តទៅជាបន្តបន្ទាប់[60]។ ការពន្លាតគោលការណ៍ស្តីពី *វិមតិសង្ស័យត្រូវបានជាប្រយោជន៍ដល់ជនជាប់ចោទ* ចំពោះបញ្ហាច្បាប់នានាដែល "មិនច្បាស់លាស់" នៅក្នុងបរិបទនេះ នឹងធ្វើឱ្យរឹងស្ទូកដល់ការរីកចម្រើននៃច្បាប់តាមទម្លាប់អន្តរជាតិ, មានហានិភ័យយ៉ាងធ្ងន់ធ្ងរទៅលើការខូចខាតប្រយោជន៍នៃប្រព័ន្ធច្បាប់អន្តរជាតិ។ ដូចដែលរដ្ឋអាជ្ញាមួយរូបក្នុងចំណោមរដ្ឋអាជ្ញានាំមុខនានានៅ តុលាការនូរ៉ាំប៊ឺហ្គ បានដាស់តឿនថា៖

> "បើយើងច្រានចោលច្បាប់អន្តរជាតិ វៀរលែងតែវាត្រូវបានតំណាងនៅក្នុងក្រម និងលក្ខន្តិកៈនានា, ដោយមានទាំងអស់នៃប្រព័ន្ធយុត្តិធម៌ទំនើប, យើងមិនដែលរកឃើញវាទាល់តែសោះព្រោះវាមិនអាចមានអត្ថិភាពនៅក្នុងទម្រង់នេះ ដោយពុំមានអង្គការនយោបាយពិភពលោកមួយ ដែលមានការលូតលាស់ខ្ពង់ខ្ពស់ស្របគ្នាបាននោះទេ។

[59] សេចក្តីសំរេចរបស់ អជតក លើសំណើសុំដោះលែងរបស់ ខៀវសំផន, កថាខណ្ឌទី៣១។

[60] *សូមមើល, រដ្ឋអាជ្ញា ទល់នឹង Delalic, Mucic, Delic & Landzo*, សាលក្រម, សំណុំរឿងលេខ IT-96-21-T, អង្គជំនុំជម្រះសាលាដំបូង ICTY, ថ្ងៃទី១៦ វិច្ឆិកា ១៩៩៨, កថាខណ្ឌទី ៤០៥ (ដោយកត់សម្គាល់ថា ការអនុវត្ត និងបទដ្ឋាននៃគោលការណ៍នីត្យានុកូលភាពអាចផ្សេងគ្នារវាងច្បាប់ព្រហ្មទណ្ឌអន្តរជាតិ ជាមួយនឹងប្រព័ន្ធជាតិ ហើយថាគោលបំណងនៃគោលការណ៍នីត្យានុកូលភាពដូចដែលបានអនុវត្តនៅក្នុងប្រព័ន្ធអន្តរជាតិ "ទំនងជាខុសគ្នា ក្នុងគោលបំណងដ៏ជាក់ច្បាស់នៃការរក្សាតុល្យភាពរវាង ការរក្សានូវយុត្តិធម៌ និងភាពត្រឹមត្រូវចំពោះជនជាប់ចោទ ជាមួយនឹងការពិចារណាពីការរក្សាទុកនូវសណ្តាប់ធ្នាប់ពិភពលោក"។

តាមពិតទៅ វាគឺពិតជាកើតមកពីដំណើរការនៃការអនុវត្តច្បាប់ ដែលស្ថាប័ននយោបាយនានាបានបង្កើតឡើង”[61]។

៣២- យ៉ាងហោចណាស់ ការអនុវត្តបែបណាមួយក៏ដោយស្តីពីការសម្រេចលើបញ្ហាពិបាកៗ ឬ “មិនច្បាស់លាស់” ទាក់ទងទៅនឹងច្បាប់តាមទម្លាប់អន្តរជាតិ ដើម្បីជាប្រយោជន៍ដល់ជនជាប់ចោទគួរតែត្រូវបានកម្រិតឲ្យនៅត្រឹមតែ *កាលៈទេសៈលើកលែង* បានហើយកាលណាមិនមានវិធានផ្សេងៗឯណាដែលស្តីពីការបកស្រាយ អាចជួយរកដំណោះស្រាយលើបញ្ហានោះបាន និងកាលណាបញ្ហាស្តីពីភាពត្រឹមត្រូវយ៉ាងខ្លាំងនោះ មានភាពធ្ងន់ជាងការចាំបាច់ក្នុងការជំទាស់ ដើម្បីរក្សានូវប្រព័ន្ធយុត្តិធម៌ព្រហ្មទណ្ឌអន្តរជាតិមួយដែលអាចដំណើរការបាន។ *កាលៈទេសៈលើកលែង*បែបដូច្នេះ មិនមានអត្ថិភាពទេនៅទីនេះ។

## V. សេចក្តីសន្និដ្ឋាន

៣៣- ចំពោះមូលហេតុនានាដែលមានចែងនៅខាងលើនេះ សហព្រះរាជអាជ្ញាសូមស្នើឲ្យ អង្គជំនុំជម្រះសាលាដំបូង៖ ទី១) ធ្វើវិសោធនកម្មលើនិយមន័យនៃឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ នៅក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះមួយដែលបានកែប្រែ ដោយមិនរាប់បញ្ចូលនូវលក្ខខណ្ឌតម្រូវស្តីពីទំនាក់ទំនងនៃជម្លោះប្រដាប់អាវុធដែលអង្គបុរេជំនុំជម្រះបានដាក់បន្ថែម, និង ទី២) ឲ្យអង្គជំនុំជម្រះសាលាដំបូង សម្រេចសេចក្តី ទៅលើសំណើរបស់សហព្រះរាជអាជ្ញា ឲ្យបានមុនពេលចាប់ផ្តើមដំណើរការនីតិវិធី ឬក៏ជូនដំណឹងថាខ្លួនបានទទួលយកសំណើរបស់សហព្រះរាជអាជ្ញា ដោយអនុលោមតាមការផ្តល់ទស្សនទាននេះ៕

| កាលបរិច្ឆេទ | ឈ្មោះ | ទីកន្លែង | ហត្ថលេខា |
|---|---|---|---|
| ថ្ងៃទី១៥ ខែមិថុនា ឆ្នាំ២០១១ | **លោក យ៉េត ចរិយា**<br>សហព្រះរាជអាជ្ញារង | ភ្នំពេញ | |
| | **លោក** Andrew CAYLEY<br>សហព្រះរាជអាជ្ញា | | |

[61] Telford Taylor, របាយការណ៍ចុងក្រោយជូនទៅលេខាកងទ័ព ស្តីពីការកាត់សេចក្តីលើឧក្រិដ្ឋកម្មសង្គ្រាមនៅ Nuremberg ក្រោមច្បាប់លេខ១០របស់ក្រុមប្រឹក្សាត្រួតពិនិត្យ, ថ្ងៃទី១៥ សីហា ១៩៤៩, ត្រង់ ២២១ ។